# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រម


១៦-៣-២០០៥ -ព្រះរាជក្រម នស/រកម/០៣០៥/០០៤ ច្បាប់ស្តីពីការទូទាត់ថវិការបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ២២៣២

០២-៤-២០០៥ -ព្រះរាជក្រម នស/រកម/០៤០៥/០០៧ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល ២២៤៣


## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


១១-៤-២០០៥ -អនុក្រឹត្យលេខ ៣៧១ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៣១១

១១-៤-២០០៥ -អនុក្រឹត្យលេខ ៣៧២ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ២៣១៨

១១-៤-២០០៥ -អនុក្រឹត្យលេខ ៣៧៣ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៣១៩


## III~ការិយាល័យបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


១២-៤-២០០៥ -ប្រកាសលេខ ២២២ សហវ.ប្រក ស្តីពីការបង្កើតគណៈកម្មាធិការសីលធម៌វិជ្ជាជីវៈប្រចាំវិទ្យាស្ថានគណនេយ្យករជំនាញ និង សវនករកម្ពុជា ២៣២១

១៣-៤-២០០៥ -ប្រកាសលេខ ២២៣សហវ.ប្រក ស្តីពីការបង្កើតក្រុមការងាររៀបចំមាតិកាគណនេយ្យ និង ថវិកាថ្មី ២៣២៤


### ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ


០៧-៤-២០០៥ -ប្រកាសលេខ ១៩៤ ប្រក.កសក ស្តីពីការបង្កើតឯកសណ្ឋាន និង សញ្ញាសម្គាល់របស់មន្ត្រីរាជការ នៃនាយកដ្ឋាននីតិកម្មកសិកម្ម និង មន្ទីរកសិកម្មខេត្ត ក្រុង ២៣២៩


### ៣~ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


២៣-៣-២០០៥ -លិខិតលេខ ៦៧៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អាយអិនជី ហូលឌីង** ២៣៣៧

៣០-៣-២០០៥ -លិខិតលេខ ៧២៣ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេកសែប គ្រុប** ២៣៣៩

៣០-៣-២០០៥ -លិខិតលេខ ៧២៤ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**គុន.គុក (ខេមបូឌា)** ២៣៤១

៣០-៣-២០០៥ -លិខិតលេខ ៧៣២ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**សូភីទុន ត្រេដ** ២៣៤២

៣០-៣-២០០៥ -លិខិតលេខ ៧៣៣ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**បញ្ញាចន្ទន៍** ២៣៤៤

៣០-៣-២០០៥ -លិខិតលេខ ៧៣៨ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ធីនីម៉ិច** ២៣៤៦

៣០-៣-២០០៥ -លិខិតលេខ ៧៤១ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ខេ.អិន.ធី ប្រូឌើរ** ២៣៤៨

៣០-៣-២០០៥ -លិខិតលេខ ៧៤២ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ម៉ូខែន ឌីវេឡុបមេន ទើលដ៍** ២៣៥០

៣១-៣-២០០៥ -លិខិតលេខ ៧៤៤ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ថៃយ៍ ជូ** ២៣៥២

៣១-៣-២០០៥ -លិខិតលេខ ៧៤៨ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**(ខេមបូឌា) តាំងណាំ ឆាយណា ខេភេនី អិលធីឌី** ២៣៥៤

៣១-៣-២០០៥ -លិខិតលេខ ៧៥៨ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**យូរ៉ុប ហ្វាម៉ា** ២៣៥៦

៣១-៣-២០០៥ -លិខិតលេខ ៧៥៩ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឌី.ធី.ឌី (ខេមបូឌា)** ២៣៥៨

៣១-៣-២០០៥ -លិខិតលេខ ៧៦០ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឆាន ហំរ** ២៣៦០

០១-៤-២០០៥ -លិខិតលេខ ៧៦៣ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ីគ្រេត គ្រុប** ២៣៦២

០៤-៤-២០០៥ -លិខិតលេខ ៧៦៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អេ.ទី.អិន.ភី អ៊ីមផត អិចផត** ២៣៦៤

០៤-៤-២០០៥ -លិខិតលេខ ៧៦៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ម៉ុង លាំង គ្រុប** ២៣៦៦

០៤-៤-២០០៥ -លិខិតលេខ ៧៧០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ណាទី ឡុងប៊ិច អ៊ីមផត អិចផត** ២៣៦៨

## ៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

០៦-៤-២០០៥ -ប្រកាសលេខ ៤៨៥ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ក្រាំងស្រម៉ ស្ថិតនៅក្នុងឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ២៣៧០

០៦-៤-២០០៥ -ប្រកាសលេខ ៤៨៦ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ លង្វែក ស្ថិតនៅក្នុង ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ២៣៧១

០៦-៤-២០០៥ -ប្រកាសលេខ ៤៨៧ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ អ្នកតាហាង ស្ថិតនៅក្នុងឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ២៣៧២

០៦-៤-២០០៥ -ប្រកាសលេខ ៤៨៨ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ខ្លាគ្រហឹម ស្ថិតនៅក្នុងឃុំអំពិលទឹក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ២៣៧៣

០៦-៤-២០០៥ -ប្រកាសលេខ ៤៨៩ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ សែប ស្ថិតនៅក្នុងឃុំសែប ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ២៣៧៤

០៦-៤-២០០៥ -ប្រកាសលេខ ៤៩០ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ក្រាំងស្គារ ស្ថិតនៅក្នុងឃុំ ក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ២៣៧៥

០៦-៤-២០០៥ -ប្រកាសលេខ ៤៩១ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ទឹកជុំ ស្ថិតនៅក្នុងឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ២៣៧៦

០៦-៤-២០០៥ -ប្រកាសលេខ ៤៩២ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ ផ្សារត្រាច ស្ថិតនៅក្នុងឃុំស្វាយ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ២៣៧៧

# ព្រះរាជក្រម

នស/រកម/០៣០៥/០០៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្ រ្តីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០១/នស/១៩៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០០២ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ការទូទាត់ថវិកាទូទៅរបស់រដ្ឋ

# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២

3112

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានយល់ព្រមតាមការអនុវត្តនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០១ ។ ការអនុវត្តនេះ លេចចេញជាលទ្ធផលដូចមានចែងក្នុងតារាងសរុបខាងក្រោមនេះ ៖

ឯកតា : លានរៀល

| កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០២ | ការអនុវត្តថវិកា ឆ្នាំ ២០០២ |
|---|---|---|
| សរុបចំណូល [១] | ២.៦៣៦.០០០ | ២.៩៧៣.៥០១ |
| សរុបចំណាយ | ២.៦៣៦.០០០ | ២.៩៧២.៣៤២ |
| ចំនួនអតិរេកនៃគណនេយ្យចំណូល/ចំណាយ | — | + ១.១៥៩ |
| កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាដែលបាន អនុវត្តដោយរតនាគារជាតិ | | |
| ចំណូលថវិកា | ១.៩៣៦.០០០ | ១.៩២៣.៨៦៨ |
| • ចំណូលចរន្ត | ១.៧៩១.០០០ | ១.៧២៧.៨៩៨ |
| • ចំណូលជាមូលធនក្នុងប្រទេស | ២៥.០០០ | ១៦.៣០៥ |
| • ចំណូលជាមូលធនក្រៅប្រទេស | ១២០.០០០ | ១៧៩.៦៦៥ |
| ចំណាយថវិកា | ១.៩៣៦.០០០ | ១.៩២២.៤០៩ |
| • ចំណាយចរន្ត | ១.៥៧៦.០០០ | ១.៥៧៤.១១៤ |
| • ចំណាយជាមូលធន | ៣៦០.០០០ | ៣៤៨.២៩៦ |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលបានអនុវត្តក្រៅរតនាគារជាតិ | | |
| • ធនធានជាមូលធនសំរាប់គំរោងដោយ ហិរញ្ញប្បទាន ក្រៅប្រទេសផ្ទាល់ | ៧០០.០០០ | ១.០៤៩.៩៣៣ |
| • ចំណាយជាមូលធនដោយធនធាន សំរាប់ គំរោងដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៧០០.០០០ | ១.០៤៩.៩៣៣ |

(១) ក្នុងនោះមានវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលបានលើកឡើងនេះ គ្រាន់តែជាការបញ្ចូលបញ្ជាល្បុំប៉ុណ្ណោះ ពីព្រោះកិច្ចប្រតិបត្តិការដែលបានអនុវត្តផ្ទាល់ដោយហិរញ្ញប្បទានក្រៅប្រទេស មិនឆ្លងកាត់រតនាគារជាតិ និង មិនបានចុះកិច្ចបញ្ជីការគណនេយ្យ នៅក្នុងគោរមារតនាគារជាតិទេ កិច្ចប្រតិបត្តិការនេះ គឺជាលទ្ធផលដែលសំរេចបានដោយមានទំនាក់ទំនងផ្ទាល់ ជាមួយអ្នកផ្ដល់មូលនិធិ ។

**មាត្រា ២.-**

ចំណូលថវិកា ដែលបានអនុវត្តដោយរតនាគារជាតិ ត្រូវបានលំអិតតាមមាតិកាថវិកា នៅក្នុងតារាង "ក" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

ចំណាយថវិកា ដែលបានអនុវត្តដោយរតនាគារជាតិ ក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០២ ត្រូវបានលំអិតតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែល និង តាមជំពូកនៅក្នុង តារាង "ខ" ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

តារាង "១១" ដែលភ្ជាប់មកជាមួយច្បាប់នេះ គឺជាបញ្ជីនៃចំណាយវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្នុងប្រទេស ដែលសំរេចបានក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០២ និងដែល បានបែងចែកតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែល ។

លទ្ធផលសំរេចបានស្តីពីវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០២ ចំពោះចំណូលត្រូវបានលំអិតតាមមាតិកាថវិកាដូចមាន នៅក្នុងភាគទី II នៃតារាង "ក" និងចំពោះចំណាយត្រូវបានលំអិតនៅក្នុងតារាង "១២" ដូចមានជូនភ្ជាប់មកជាមួយច្បាប់នេះ ។

## ជំពូកទី ២
## បទប្បញ្ញត្តិ
## ស្តីពីកិច្ចប្រតិបត្តិការថវិកា

**មាត្រា ៣.-**

ការប្រមូលចំណូល ជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋពីពន្ធដារ វិភាគទាន អាករ ផលិតផល និង ផលទុន ព្រមទាំងការសំរេចបាននូវអំណោយ មូលនិធិឧបត្ថម្ភ និង ធនធានដែលបានមកពីការខ្ចី ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២ ។

មានចំនួនទឹកប្រាក់សរុប.................................................១.៩៣៦.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់.....................១.៩២៣.៥៦៨ លានរៀល

ដូច្នេះមានចំណូលខ្វះចំនួន.........................(-) ១២.៤៣២ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តន៍ដូចតទៅ ៖

ចំណូលចរន្ត :

- គំរោង............................ ១.៧៩១.០០០ លានរៀល
- ការសំរេចបាន.......... ១.៧២៧.៥៩៨ លានរៀល
- មានចំនួនខ្វះ.......... (-) ៦៣.៤០២ លានរៀល

ចំណូលជាមូលធនក្នុងប្រទេស :

- គំរោង.................................. ២៥.០០០ លានរៀល
- ការសំរេចបាន.................. ១៦.៣០៥ លានរៀល
- មានចំនួនខ្វះ................ (-) ៨.៦៩៥ លានរៀល

ចំណូលជាមូលធនក្រៅប្រទេស :

- គំរោង................................ ១២០.០០០ លានរៀល
- ការសំរេចបាន................ ១៧៩.៦៦៥ លានរៀល
- មានចំនួនលើស......... (+) ៥៩.៦៦៥ លានរៀល

មាត្រា ៤.-

ចំណាយថវិកាទូទៅរបស់រដ្ឋ ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ មានចំនួនទឹកប្រាក់សរុប.................................... ១.៩៣៦.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់.......................... ១.៩២២.៤០៩ លានរៀល

ដូច្នេះមានចំណាយខ្វះឥណទានថវិកាចំនួន.......... (-)១៣.៥៩១ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តន៍ដូចតទៅ ៖

ចំណាយចរន្ត :

- គំរោង.............................. ១.៥៧៦.០០០ លានរៀល
- ការសំរេចបាន............ ១.៥៧៤.១១៤លានរៀល
- មានចំនួនខ្វះ...................... (-)១.៨៨៦ លានរៀល

ចំណាយជាមូលធននៃវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្នុងប្រទេស :

- គំរោង................................ ៣៦០.០០០ លានរៀល
- ការសំរេចបាន................ ៣៤៨.២៩៦ លានរៀល
- មានចំនួនខ្វះ............... (-)១១.៧០៤ លានរៀល

ចំណាយជាមូលធននៃការរំលស់បំណុល :

- គំរោង.................................... ២៥.០០០ លានរៀល
- ការសំរេចបាន........................ ៩.១២៧ លានរៀល
- មានចំនួនខ្វះ............... (-)១៥.៨៧៣ លានរៀល

**មាត្រា ៥.-**

ការអនុវត្តកិច្ចប្រតិបត្តិការចំណូល និង ចំណាយតាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ដែលបានសំរេចដោយរតនាគារជាតិដូចមានចែងនៅក្នុងមាត្រា ៣ និង មាត្រា ៤ នៃច្បាប់នេះ បានបង្ហាញជាលទ្ធផលនូវអតិរេកគណនេយ្យនៃចំណូល និង ចំណាយដូចតទៅ ៖

- ចំណូលថវិកា ដែលបានសំរេចដោយរតនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ មានចំនួន.................................................................... ១.៩២៣.៥៦៨ លានរៀល
- ចំណាយថវិកា ដែលបានសំរេចដោយរតនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ មានចំនួន.................................................................... ១.៩២២.៤០៩ លានរៀល
- អតិរេកគណនេយ្យពិតនៃចំណូល និងចំណាយ.... (+)១.១៥៩លានរៀល

អតិរេកគណនេយ្យនេះ គឺជាលទ្ធផលនៃ :

- អតិរេកនៃចំណូលចរន្ត និង ចំណាយចរន្ត (+)១៥៣.៤៨៤ លានរៀល
- និងឱនភាពនៅក្នុងកិច្ចប្រតិបត្តិការជាមូលធន.. (-)១៥២.៣២៥លានរៀល

ដោយអនុលោមទៅតាមបទប្បញ្ញត្តិក្នុងមាត្រា ៥៧ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ ន.ស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ អតិរេកគណនេយ្យនៃចំណូល និង ចំណាយសំរាប់ការគ្រប់គ្រងឆ្នាំ២០០២ មានចំនួនទឹកប្រាក់ (+) ១.១៥៩ លានរៀល ត្រូវបានកត់ត្រានៅក្នុងគណនីលទ្ធផល ដែលបានបើកនៅក្នុងលេខនាធិការនៃរតនាគារជាតិ ។

# ជំពូកទី ៣
# បទប្បញ្ញត្តិ
# ស្តីពីវិនិយោគសាធារណៈ
# ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់
# ដែលបានអនុវត្តក្រៅរតនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២

**មាត្រា ៦.-**

វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលបានអនុវត្តក្រៅរតនាគារជាតិ និងដែលបានគ្រោងទុក សរុបចំណូលស្មើនឹងសរុបចំណាយសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ មានចំនួនទឹកប្រាក់.................................................. ៧០០.០០០ លានរៀល

ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់.......................... ១.០៤៩.៩៣៣ លានរៀល

ដូច្នេះមានចំនួនលើស.................................... (+)៣៤៩.៩៣៣ លានរៀល

# ជំពូកទី ៤
# បទប្បញ្ញត្តិស្តីពី
# តុល្យភាពហិរញ្ញវត្ថុសាធារណៈ
# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២

**មាត្រា ៧.-**

តុល្យភាពហិរញ្ញវត្ថុសាធារណៈជាស្ថាពរនៃថវិកាទូទៅរបស់រដ្ឋ បានបង្ហាញនូវប្រភេទនៃកិច្ចប្រតិបត្តិការដូចតទៅ ៖

- កិច្ចប្រតិបត្តិការថវិកា : តារាង “ក” : ចំណូលថវិកាទូទៅរបស់រដ្ឋ និងតារាង “ខ” ចំណាយថវិកាទូទៅរបស់រដ្ឋ ។
- កិច្ចប្រតិបត្តិការនៃរតនាគារជាតិ ។
- ទំនាក់ទំនងហិរញ្ញវត្ថុរបស់រដ្ឋ ជាមួយនឹងធនាគារជាតិនៃកម្ពុជា ។

តុល្យភាពហិរញ្ញវត្ថុដែលសំរេចបានជាស្ថាពរ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ បានឆ្លុះបញ្ចាំងនៅក្នុងតារាង នៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ ដូចខាងក្រោម ៖

ឯកតា :លានរៀល

| តារាងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ | ចំនួនទឹកប្រាក់ | ចំនួនលើស (+)/ ឱនភាព (-) |
|---|---|---|
| I- ចំណូលក្នុងប្រទេស | ១.៧៤៣.៩០៣ | |
| ១.ចំណូលចរន្ត | ១.៧២៧.៥៩៨ | |
| ២.ចំណូលជាមូលធនក្នុងប្រទេស (ឯកជនភាវូបនីយកម្ម) | ១៦.៣០៥ | |
| II- ចំណាយថវិកា | ២.៨៦៣.២១៥ | |
| ១.ចំណាយចរន្ត | ១.៤៧៤.១១៤ | |
| ២.ចំណាយជាមូលធន [២] | ១.៣៨៩.១០១ | |
| ក្នុងនោះ : | | |
| ❖ វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ៣៣៨.៣៦៨ | |
| -ដោយមូលនិធិថវិកា | ២៨១.៤២០ | |
| • គំរោងវិនិយោគ (សាងសង់, ទិញសម្ភារៈ) | ២៣០.៩៩៨ | |
| • បដិភាគរួមចំណែកជាមួយវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៥០.៤២២ | |
| -ដោយមូលនិធិក្រៅប្រទេសដែលមានការយល់ព្រមជាមុនពីអ្នកផ្តល់ជំនួយ | ៥៦.៩៤៨ | |
| ❖ វិនិយោគសាធារណៈដោយហិរញ្ញប្បទានពីក្រៅប្រទេសផ្ទាល់(ជំនួយគំរោងការ) | ១.០៤៩.៩៣៣ | |
| អតិរេកនៃថវិកាចរន្ត (តាមនិយមន័យសន្សាផ្តល់) | | (+)១៥៣.៤៨៤ |
| ឱនភាពនៃថវិកាទូទៅ (តាមនិយមន័យសន្សាផ្តល់) | | (-)១.២១៩.៣១២ |
| III-កំណែតំរូវ | | (+)១៤.៩៣៩ [៣] |
| អតិរេកនៃថវិកាចរន្ត (តាមនិយមន័យបេឡា) | | (+)១៦៨.៩២៣ |
| ឱនភាពនៃថវិកាទូទៅ (តាមនិយមន័យបេឡា) | | (-)១.២០៤.៣៣៣ |
| IV- ហិរញ្ញប្បទាននៃឱនភាព | | (+)១.២០៤.៣៣៣ |
| ១. ហិរញ្ញប្បទានក្រៅប្រទេស | | (+)១.២៥០.៨៤៩ |
| • ជំនួយទ្រទ្រង់ថវិកាដែលមានការយល់ព្រមជាមុនពីអ្នកផ្តល់ជំនួយ | | (+)១៧៩.៦៦៥ |
| • ជំនួយគំរោងការ | | (+)១.០៧៩.១៣៩ [៤] |
| • ការរំលស់បំណុលបរទេស | | (-)៧.៩៩៤ |
| ២. ហិរញ្ញប្បទានក្នុងប្រទេស | | (-)១៦០.៥៩០ |
| • ហិរញ្ញប្បទានធនាគារ | | (-)១០៤.៧៩៤ |
| ក្នុងនោះ -ខ្ចីពីធនាគារ | | - |
| -ការរំលស់បំណុលក្នុងប្រទេស | | (-)១.១៦៣ |
| • ប្រាក់បញ្ញើផ្សេងៗទៀតនៃរតនាគារ | | (-)៦.៩៦១ |
| • វិស័យឯកជន | | (-)៤៥.៩៩២ |
| • លំអៀងគណនីរវាងធនាគារជាតិ និង ហិរញ្ញវត្ថុ | | (-)២.៥៩៣ |
| ៣. កិច្ចប្រតិបត្តិការកំពុងដំណើរការ | | (+)១១៣.៧៦៤ |

---

[២] មិនបានគិតការរំលស់បំណុល ៩.១២៧ លានរៀល។

[៣] ចំណុចលម្អិតនៃអាណត្តិបើកប្រាក់ ដែលមានសល់មិនទាន់បានបើកផ្តល់នៅរតនាគារ និង បុរេប្រទានត្រូវធ្វើនិយ័តភាវូបនីយកម្ម។

[៤] ក្នុងនោះមានទឹកប្រាក់ចំនួន ២៩.២០៥ លានរៀល ត្រូវរង់ចាំការប្រើប្រាស់ ។

# ជំពូកទី ៥
# បទប្បញ្ញត្តិស្តីពី
# ការទូទាត់ថវិការបស់ខេត្ត ក្រុង
# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២

## មាត្រា ៨.-

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ១៨ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យ-សម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម.០២៩៨.០៣, ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ និង មាត្រា ១២ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ត្រូវបានយល់ព្រមតាមការអនុវត្ត នូវកិច្ចប្រតិបត្តិការចំណូល និងចំណាយថវិការបស់ខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ដែលលេចចេញជាលទ្ធផលដូចបានបង្ហាញនៅក្នុងតារាងខាងក្រោមនេះ ៖

ឯកតា : រៀល

| កិច្ចប្រតិបត្តិការចំណូល និង ចំណាយថវិការបស់ខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០២ | ការអនុវត្តថវិកាខេត្ត ក្រុងឆ្នាំ ២០០២ | លើស(+) ខ្វះ (-) |
|---|---|---|---|
| សរុបចំណូល | ៧៥.000.000.000 | ៨១.៥៥៤.២៩៧.១៩៣ | +៦.៥៥៤.២៩៧.១៩៣ |
| សរុបចំណាយ | ៧៥.000.000.000 | ៧៩.៧៤៥.៩៤៣.៨០៨ | +៤.៧៤៥.៩៤៣.៨០៨ |
| អតិរេកគណនេយ្យនៃចំណូល និង ចំណាយ | | ១.៨០៨.៣៥៣.៣៨៥ | +១.៨០៨.៣៥៣.៣៨៥ |
| កិច្ចប្រតិបត្តិការនៃថវិការបស់ខេត្ត ក្រុង | | | |
| I. ចំណូលថវិកា | ៧៥.000.000.000 | ៨១.៥៥៤.២៩៧.១៩៣ | +៦.៥៥៤.២៩៧.១៩៣ |
| – ចំណូលចរន្ត | ៧៥.000.000.000 | ៨១.៥៥០.៧៨៧.១៩៣ | ៦.៥៥០.៧៨៧.១៩៣ |
| • ចំណូលសារពើពន្ធ | ៣៦.000.000.000 | ៤១.៧៧៦.២៣១.៧៥៦ | +៥.៧៧៦.២៣១.៧៥៦ |
| • ចំណូលពុំមែនសារពើពន្ធ | ៨.000.000.000 | ៨.៣៦៩.៥៥៥.៤៣៧ | +៣៦៩.៥៥៥.៤៣៧ |
| • ឧបត្ថម្ភពីថវិការដ្ឋ | ៣១.000.000.000 | ៣១.៤០៥.000.000 | +៤០៥.000.000 |
| – ចំណូលជាមូលធន | 0 | ៣.៥១0.000 | +៣.៥១0.000 |
| • ចំណូលជាមូលធនផ្ទៃក្នុង | 0 | ៣.៥១0.000 | +៣.៥១0.000 |
| • ចំណូលជាមូលធននៃវិនិយោគដោយថវិការដ្ឋ (កម្មវិធីសិលា) | 0 | 0 | 0 |
| II. ចំណាយថវិកា | ៧៥.000.000.000 | ៧៩.៧៤៥.៩៤៣.៨០៨ | +៤.៧៤៥.៩៤៣.៨០៨ |
| – ចំណាយចរន្ត | ៧៥.000.000.000 | ៧៩.៧៤៥.៩៤៣.៨០៨ | +៤.៧៤៥.៩៤៣.៨០៨ |
| – ចំណាយជាមូលធន | 0 | 0 | 0 |
| III. អតិរេកថវិកា | 0 | ១.៨០៨.៣៥៣.៣៨៥ | +១.៨០៨.៣៥៣.៣៨៥ |

**មាត្រា ៩.-**

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ២២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យ-សម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស.រកម.០២៩៨.០៣, ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ អតិរេកនៃថវិការបស់ខេត្ត ក្រុង ដែលមានចំនួនទឹកប្រាក់ ១.៨០៨.៣៥៣.៣៨៥ រៀល ត្រូវបានបង់ចូលថវិកាទូទៅរបស់រដ្ឋ ។

## ជំពូកទី ៦
## បទប្បញ្ញត្តិស្តីពី
## និយ័តភាវូបនីយកម្ម
## នៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែម
## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២

**មាត្រា ១០.-**

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ៤៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះ-រាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ផ្អែកតាមលិខិតលេខ ៣៧៦ រស ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៣ របស់រដ្ឋសភា ត្រូវបានអនុម័តយល់ព្រមផ្តល់ឥណទានថវិកាបន្ថែមដល់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ចំនួន ៣.០៧២ លានរៀល សំរាប់ចំណាយរៀបចំកិច្ចប្រជុំកំពូលអាស៊ានឆ្នាំ ២០០២ ។



11/12

## អវសានប្បញ្ញត្តិ

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១២.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.០៥០៣.១៤១

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

លេខ ៖ ១៦៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ [illegible] ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ាវី តាន់**

12/12

# ព្រះរាជក្រម

នស/រកម/០៤០៥/០០៧

## យើង

## ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រត្តិបត្តិការអន្តរជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៥ នាសម័យ ប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល

**មាត្រា ១.-**

អនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល ដែលធ្វើនៅទីក្រុងវីយែន នាថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៦៣ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស.រកម.០៤០៤.១៧៨

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង
សហប្រតិបត្តិការអន្តរជាតិ
ហត្ថលេខា
ហោ ណាំហុង

លេខ: ០៥២ ច.ល
[illegible]
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៥
[illegible]រាជរដ្ឋាភិបាល
ណារី តាន់

# អនុសញ្ញាក្រុងវីយែន
# ស្តីពី
# ទំនាក់ទំនងកុងស៊ុល

បណ្តារដ្ឋភាគីនៃអនុសញ្ញានេះ :

ដោយរំលឹកឃើញថា តាំងពីយុគសម័យដ៏យូរលង់មកហើយ ទំនាក់ទំនងកុងស៊ុលបានកើតមានរវាងប្រជាជនទាំងឡាយ

ដោយចាប់អារម្មណ៍ទៅលើគោលបំណង និង គោលការណ៍របស់ធម្មនុញ្ញសហប្រជាជាតិស្តីពីអធិបតេយ្យ សមភាពនៃរដ្ឋទាំងឡាយ ការរក្សាសន្តិភាពនិងសន្តិសុខអន្តរជាតិ និង ការជំរុញឱ្យមានទំនាក់ទំនងជាមិត្តភាព រវាងប្រជាជាតិទាំងឡាយ

ដោយសង្កេតឃើញថា សន្និសីទសហប្រជាជាតិស្តីពីទំនាក់ទំនងការទូត និង អភ័យឯកសិទ្ធិការទូត បានអនុម័តលើអនុសញ្ញាក្រុងវីយែនស្តីពីទំនាក់ទំនងការទូត ដែលបានបើកអោយចុះហត្ថលេខានៅថ្ងៃទី ១៨ មេសា ១៩៦១

ដោយយល់ឃើញថា អនុសញ្ញាអន្តរជាតិ ស្តីពីទំនាក់ទំនង បុព្វសិទ្ធ និងអភ័យឯកសិទ្ធិកុងស៊ុលនឹងរួមវិភាគទានជួយសំរួលដល់ទំនាក់ទំនងជាមិត្តភាពរវាងប្រទេសទាំងអស់ទោះជាមានរបបធម្មនុញ្ញ និង សង្គមផ្សេងៗក៏ដោយ

ដោយជឿជាក់ថា ទិសដៅនៃបុព្វសិទ្ធិ និង អភ័យឯកសិទ្ធិចែងខាងលើ មិនមែនផ្តល់អត្ថប្រយោជន៍ដល់បុគ្គលទេ ក៏ប៉ុន្តែសំរាប់ធានាបាននូវការបំពេញមុខងារប្រកបដោយប្រសិទ្ធិភាពដល់បណ្តាប៉ុស្តិ៍កុងស៊ុលទាំងឡាយក្នុងនាមរដ្ឋរៀងៗខ្លួន

ដោយអះអាងថា ក្បួនខ្នាតនៃច្បាប់អន្តរជាតិដែលធ្លាប់ប្រើប្រាស់ជាប្រពៃណីមកហើយនឹងបន្តគ្រប់គ្រងបណ្តាបញ្ហាទាំងឡាយ ដែលពុំត្រូវបានបញ្ជាក់ច្បាស់លាស់ដោយបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ

បានព្រមព្រៀងគ្នាដូចតទៅ :

## មាត្រា ១
## និយមន័យ

១- ក្នុងក្របខ័ណ្ឌនៃអនុសញ្ញានេះ ពាក្យទាំងឡាយខាងក្រោមនេះមានន័យដូចតទៅ:

ក- "បុស្តិ៍កុងស៊ុល" គឺជាស្ថានអគ្គកុងស៊ុល-ស្ថានកុងស៊ុល-ស្ថានកុងស៊ុលរង ឬ ទីភ្នាក់ងារកុងស៊ុល ។

ខ- "មណ្ឌលកុងស៊ុល" គឺជាតំបន់ដែលកំណត់អោយបុស្តិ៍កុងស៊ុល ដើម្បីបំពេញមុខងាររបស់ខ្លួន ។

គ- "ប្រធានបុស្តិ៍កុងស៊ុល" គឺជនទទួលបន្ទុកបំពេញមុខងារនៃតំណែងនេះ ។

ឃ- "មន្ត្រីកុងស៊ុល" គឺជនណាដែលទទួលបន្ទុក បំពេញមុខងារកុងស៊ុលដោយគិតទាំងប្រធានបុស្តិ៍កុងស៊ុលផងដែរ ។

ង- "និយោជិតកុងស៊ុល" គឺជនណាដែលបំរើការក្នុងកិច្ចការរដ្ឋបាល ឬ បច្ចេកទេសនៃបុស្តិ៍កុងស៊ុល ។

ច- "សមាជិកនៃបុគ្គលិកបំរើការ" គឺជនដែលបំពេញការងារជាអ្នកបំរើនៅក្នុងបុស្តិ៍កុងស៊ុល

ឆ- "សមាជិកកុងស៊ុល" គឺបណ្តាមន្ត្រីកុងស៊ុល-និយោជិតកុងស៊ុល និងសមាជិក នៃបុគ្គលិកបំរើការ ។

ជ- "សមាជិកនៃបុគ្គលិកកុងស៊ុល" គឺបណ្តាមន្ត្រីកុងស៊ុល ក្រៅពីប្រធានកុងស៊ុល និយោជិតកុងស៊ុល និងសមាជិកនៃបុគ្គលិកបំរើការ ។

ឈ- "សមាជិកនៃបុគ្គលិកឯកជន" គឺជាជនណាម្នាក់ដែលបំរើការដាច់ដោយឡែកអោយកិច្ចការឯកជនរបស់សមាជិកណាម្នាក់នៃបុស្តិ៍កុងស៊ុល ។

ញ- "ទីស្ថានកុងស៊ុល" ជាអាគារ ឬ បណ្តាផ្នែកនៃអាគារ និងផ្ទៃដីបន្តភ្ជាប់ ទោះជាកម្មសិទ្ធិរបស់ជនណាក៏ដោយ ដែលត្រូវប្រើប្រាស់ដាច់មុខសំរាប់ផលប្រយោជន៍របស់បុស្តិ៍កុងស៊ុល ។

ដ- ពាក្យ "សារដ្ឋានកុងស៊ុល" គឺរាល់ក្រដាសស្នាម ឯកសារ លិខិតឆ្លងឆ្លើយ សៀវភៅ ហ្វីលខ្សែអាត់ និង បញ្ជីនៃបុស្តិ៍កុងស៊ុល រួមទាំងសំភារៈបញ្ជូនសារ និង សង្ហារឹម ដែលបុស្តិ៍កុងស៊ុលការពារ និងរក្សាទុក។

២-មន្ត្រីកុងស៊ុលមានពីរប្រភេទគឺ : មន្ត្រីកុងស៊ុលអាជីព និង មន្ត្រីកុងស៊ុលកិត្តិយស ។ បណ្តាបទបញ្ញត្តិក្នុងជំពូក២នៃអនុសញ្ញានេះអនុវត្តចំពោះស្ថានកុងស៊ុលដែលដឹកនាំដោយមន្ត្រីកុងស៊ុលអាជីព ឯបទបញ្ញត្តិទាំងឡាយនៃជំពូក៣អនុវត្តចំពោះបុស្តិ៍កុងស៊ុលដែលដឹកនាំដោយមន្ត្រីកុងស៊ុលកិត្តិយស ។

៣-សភាពលក្ខណៈពិសេសរបស់សមាជិកបុស្តិ៍កុងស៊ុល ដែលជាប្រជាជន ឬ ជនស្នាក់ជាអចិន្ត្រៃយ៍នៃរដ្ឋម្ចាស់ផ្ទះ ត្រូវបានកំណត់ដោយប្រការ ៧១ នៃអនុសញ្ញានេះ ។

## ជំពូក I

## ទំនាក់ទំនងកុងស៊ុលជាទូទៅ

### ផ្នែក ១ : ការបង្កើត និង បែបបទនៃទំនាក់ទំនងកុងស៊ុល

### ប្រការ ២

### ការបង្កើតទំនាក់ទំនងកុងស៊ុល

១- ការបង្កើតទំនាក់ទំនងកុងស៊ុលរវាងបណ្តារដ្ឋ ត្រូវធ្វើឡើងដោយមានការព្រមព្រៀងគ្នាទៅវិញទៅមក ។

២-ការព្រមព្រៀងគ្នាបង្កើតនូវទំនាក់ទំនងការទូតរវាងរដ្ឋពីរ គិតបញ្ចូលទាំងការព្រមព្រៀងគ្នានូវទំនាក់ទំនងកុងស៊ុលផងដែរ លើកលែងតែមានការបញ្ជាក់ផ្ទុយពីនេះ ។

៣- ការផ្តាច់ទំនាក់ទំនងការទូត មិនបណ្តាលអោយមានការផ្តាច់ទំនាក់ទំនងកុងស៊ុល ដោយសារហេតុការណ៍នេះទេ ។

### ប្រការ ៣

### ការបំពេញមុខងារកុងស៊ុល

ប៉ុស្តិ៍កុងស៊ុល ជាអ្នកបំពេញមុខងារកុងស៊ុល ។

បេសកកម្មការទូត ក៏ជាអ្នកបំពេញមុខងារកុងស៊ុលផងដែរដោយស្របទៅនឹង ខ ទាំងឡាយនៃអនុសញ្ញានេះ ។

### ប្រការ ៤

### ការបង្កើតប៉ុស្តិ៍កុងស៊ុល

១- ការបង្កើតនូវប៉ុស្តិ៍កុងស៊ុល នៅលើទឹកដីនៃរដ្ឋម្ចាស់ផ្ទះ អាចធ្វើទៅបានលុះត្រាតែមានការព្រមព្រៀងពីរដ្ឋនេះ ។

២- ទីស្នាក់ការនៃប៉ុស្តិ៍កុងស៊ុល ឋានន្តរសក្តិ-មណ្ឌលកុងស៊ុល គឺត្រូវបានកំណត់ឡើងដោយរដ្ឋដាក់កុងស៊ុល ហើយដាក់ជូន ស្នើការយល់ព្រមពីរដ្ឋម្ចាស់ផ្ទះ ។

៣- ការកែប្រែទៅថ្ងៃក្រោយពាក់ព័ន្ធដល់ទីកន្លែងប៉ុស្តិ៍កុងស៊ុល-ឋានានុក្រម ឬមណ្ឌលកុងស៊ុលនឹងអាចធ្វើទៅបានអាស្រ័យដោយមានការព្រមព្រៀងពីរដ្ឋម្ចាស់ផ្ទះ ។

៤- ប្រសិនបើស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលចង់បើកទីស្នាក់ការកុងស៊ុលរងមួយ ឬទីភ្នាក់ងារកុងស៊ុលនៅកន្លែងមួយផ្សេងពីមូលដ្ឋានដែលស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលតាំងនៅ គឺត្រូវឱ្យមានការព្រមព្រៀងពីរដ្ឋម្ចាស់ផ្ទះជាមុន។

៥- ការព្រមព្រៀងដោយជាក់ច្បាស់ និង ជាមុនរបស់រដ្ឋម្ចាស់ផ្ទះ ក៏តម្រូវអោយមានផងដែរ សំរាប់ការបើកនូវការិយាល័យមួយដែលជាផ្នែករបស់ប៉ុស្តិ៍កុងស៊ុលដែលមានរួចមកហើយ ហើយដែលស្ថិតនៅក្រៅទីស្នាក់ការរបស់ប៉ុស្តិ៍កុងស៊ុលនេះ ។

## ជំពូក ៥
## មុខងារកុងស៊ុល

មុខងារកុងស៊ុលរួមមាន :

ក- ការពារក្នុងរដ្ឋម្ចាស់ផ្ទះនូវផលប្រយោជន៍របស់រដ្ឋដាក់កុងស៊ុល និងផលប្រយោជន៍របស់បណ្តាអាណិកជនរបស់ខ្លួនទាំងរូបវន្តបុគ្គល និងនីតិបុគ្គលក្នុងក្របខ័ណ្ឌនៃច្បាប់អន្តរជាតិ

ខ- ធ្វើឱ្យរីកចំរើនថែមទៀតនូវទំនាក់ទំនងពាណិជ្ជកម្ម-សេដ្ឋកិច្ច-វប្បធម៌ និងវិទ្យាសាស្ត្ររវាងរដ្ឋដាក់កុងស៊ុល និងរដ្ឋម្ចាស់ផ្ទះ និងជំរុញនូវទំនាក់ទំនងជាមិត្តភាពរវាងរដ្ឋទាំងពីរស្របទៅតាម ខ ទាំងឡាយនៃអនុសញ្ញានេះ

គ- ស្វែងយល់តាមគ្រប់មធ្យោបាយស្របច្បាប់ពីលក្ខណៈ និង ការអភិវឌ្ឍន៍ខាងវិស័យពាណិជ្ជកម្មសេដ្ឋកិច្ច វប្បធម៌ និង វិទ្យាសាស្ត្រនៃរដ្ឋម្ចាស់ផ្ទះ ធ្វើរបាយការណ៍ពីបញ្ហាទាំងនេះទៅរដ្ឋាភិបាលនៃរដ្ឋដាក់កុងស៊ុល និង ជូនពត៌មានទៅជនទាំងឡាយដែលពាក់ព័ន្ធនឹងការងារនេះ

ឃ- ផ្តល់លិខិតឆ្លងដែន និងបណ្តាឯកសារធ្វើដំណើរដល់អាណិកជននៃរដ្ឋដាក់កុងស៊ុល ព្រមទាំងទិដ្ឋាការ និង បណ្តាឯកសារសមស្របដល់ជនទាំងឡាយដែលចង់ចូលទៅក្នុងរដ្ឋដាក់កុងស៊ុល

ង- ផ្តល់ការសង្គ្រោះ និង ការឧបត្ថម្ភដល់អាណិកជន ទាំងរូបវន្តបុគ្គល និងនីតិបុគ្គលរបស់រដ្ឋដាក់កុងស៊ុល

ច- បំពេញការងារក្នុងឋានៈជាសារការី ជាមន្ត្រីអត្រានុកូលដ្ឋាន និងមុខងារប្រហាក់ប្រហែលដទៃទៀតព្រមទាំងមុខងារផ្នែករដ្ឋបាលខ្លះទៀត ប្រសិនបើច្បាប់ និងបទបញ្ញត្តិរបស់រដ្ឋម្ចាស់ផ្ទះពុំមានជំទាស់ ។

ឆ- ការពារផលប្រយោជន៍របស់អាណិកជន ទាំងរូបវន្តបុគ្គល និងនីតិបុគ្គលនៃរដ្ឋដាក់កុងស៊ុលក្នុងការទទួលមរតកនៅលើទឹកដីនៃរដ្ឋម្ចាស់ផ្ទះ ដោយអនុលោមទៅតាមច្បាប់ និងបទបញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ

ជ- ការពារក្នុងក្របខ័ណ្ឌដែលច្បាប់ និងបទបញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះបានកំណត់នូវផលប្រយោជន៍របស់ នីតិជន និងអសមត្ថជនដែលជាអាណិកជននៃរដ្ឋដាក់កុងស៊ុល ជាពិសេសកាលបើត្រូវអោយមានអាណាព្យាបាលភាពមួយ ឬ មុខងារជាអាណាព្យាបាលមួយចំពោះជនទាំងនោះ

ឈ- វៀរលែងតែមានទំលាប់អនុវត្ត និង នីតិវិធីដែលនៅជាធរមាន ហើយក្នុងរដ្ឋម្ចាស់ផ្ទះតំណាងអោយអាណិកជនរបស់រដ្ឋដាក់កុងស៊ុល ឬ ចាត់ការដើម្បីធានាការតំណាងសមស្របរបស់អាណិកជនទាំងនោះចំពោះមុខតុលាការ ឬ អាជ្ញាធរផ្សេងទៀតនៃរដ្ឋម្ចាស់ផ្ទះ ដើម្បីមានសំណូមពរយោងទៅតាមច្បាប់ និងបទបញ្ញត្តិរបស់រដ្ឋ ឱ្យមានការអនុម័តនូវវិធានការណ៍បណ្តោះអាសន្នក្នុងបំណងការពារនូវសិទ្ធិប្រយោជន៍អាណិកជនទាំងនេះ កាលបើអាណិកជនទាំងនេះមិនអាចការពារតាមពេលវេលាសមស្របនូវសិទ្ធិប្រយោជន៍របស់ខ្លួនបានដោយមូលហេតុអវត្តមាន ឬ ដោយមូលហេតុផ្សេងទៀត

ញ- បញ្ជូននូវលិខិតតុលាការ និងលិខិតក្រៅតុលាការ ឬ អនុវត្តការប្រគល់ភារកិច្ចស៊ើបអង្កេតដើម្បីប្រមូលភស្តុតាងឱ្យតុលាការរដ្ឋដាក់កុងស៊ុល ដោយយោងតាមកិច្ចព្រមព្រៀងអន្តរជាតិជាធរមាន ឬក្នុងករណីគ្មានកិច្ចព្រមព្រៀងខាងលើនេះធ្វើយ៉ាងណាអោយសមស្របជាមួយនឹងច្បាប់ និងបទបញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ

ដ- ការប្រើសិទ្ធិត្រួតពិនិត្យ និងការធ្វើអធិការកិច្ចដែលច្បាប់ និងបទបញ្ញត្តិរបស់រដ្ឋដាក់កុងស៊ុលបានកំណត់ទៅលើទូក ឬកប៉ាល់ដែលមានសញ្ជាតិរបស់រដ្ឋដាក់កុងស៊ុល និងទៅលើយន្តហោះដែលបានចុះបញ្ជីក្នុងរដ្ឋដាក់កុងស៊ុល ព្រមទាំងយានិករបស់យានទាំងនោះផង

ឋ- ផ្តល់ការឧបត្ថម្ភដល់បណ្តានាវា និងយន្តហោះដែលមានចែងក្នុងអនុវាក្យខ័ណ្ឌ "ដ" នៃ ប្រការនេះ និងដល់នាវិកនិងយានិកទាំងអស់ដោយទទួលយកការផ្តល់ពតិមានស្តីពីការធ្វើដំណើររបស់នាវាណាមួយ ពិនិត្យ និង ចុះទិដ្ឋាការលើឯកសារនាវា និងដោយពុំធ្វើអោយប៉ះពាល់ដល់សិទ្ធិអំណាចរបស់អាជ្ញាធរនៃរដ្ឋម្ចាស់ផ្ទះ ធ្វើការស៊ើបអង្កេតលើគ្រោះថ្នាក់ដែលកើតមានក្នុងពេលធ្វើដំណើរឆ្លងកាត់ និងដោះស្រាយរាល់វិវាទកម្មគ្រប់ប្រភេទរវាងនាវាបតី សេនាបតី និងបណ្តានាវិកតាមដែលច្បាប់ និងបទបញ្ញត្តិ ដែលរដ្ឋដាក់កុងស៊ុលអនុញ្ញាតអោយធ្វើ

ឌ- បំពេញរាល់មុខងារដទៃទៀតដែលរដ្ឋដាក់កុងស៊ុលប្រគល់អោយស្ថានកុងស៊ុលដែលច្បាប់ និងបទបញ្ញត្តិទាំងឡាយរបស់រដ្ឋម្ចាស់ផ្ទះមិនហាមឃាត់ ឬដែលរដ្ឋម្ចាស់ផ្ទះមិនជំទាស់ចំពោះមុខងារទាំងនោះ ឬក៏មុខងារទាំងនោះបានចែងនៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិជាធរមានរវាងរដ្ឋដាក់កុងស៊ុល និងរដ្ឋម្ចាស់ផ្ទះ ។

## ប្រ ក ា រ ៦
## ការបំពេញមុខងារកុងស៊ុលក្រៅមណ្ឌលកុងស៊ុល

ក្នុងកាលៈទេសៈពិសេសខ្លះ មន្ត្រីកុងស៊ុលអាចនឹងបំពេញមុខងារនៅក្រៅមណ្ឌលកុងស៊ុលរបស់ខ្លួនបាន ដោយមានការព្រមព្រៀងពីរដ្ឋម្ចាស់ផ្ទះ ។

## ប្រ ក ា រ ៧
## ការបំពេញមុខងារកុងស៊ុលក្នុងរដ្ឋទីបី

ក្រោយពីការជូនដំណឹងទៅបណ្តារដ្ឋដែលពាក់ព័ន្ធ ហើយបើពុំមានរដ្ឋណាមួយក្នុងចំណោមរដ្ឋទាំងនោះ ជំទាស់ទេនោះ រដ្ឋដាក់កុងស៊ុលអាចចាត់ឱ្យប៉ុស្តិ៍កុងស៊ុលដែលតាំងទីក្នុងរដ្ឋមួយទទួលបំពេញមុខងារកុងស៊ុល ក្នុងរដ្ឋមួយផ្សេងទៀត ។

## ប្រ ក ា រ ៨
## ការបំពេញមុខងារកុងស៊ុលជំនួសអោយរដ្ឋទីបី

ក្រោយពីការជូនដំណឹងដល់រដ្ឋម្ចាស់ផ្ទះហើយ បើរដ្ឋនេះមិនជំទាស់ទេនោះ ប៉ុស្តិ៍កុងស៊ុលនៃរដ្ឋដាក់ កុងស៊ុល អាចបំពេញមុខងារកុងស៊ុលជំនួសអោយរដ្ឋទីបីណាមួយក្នុងរដ្ឋម្ចាស់ផ្ទះ ។

## ប្រ ក ា រ ៩
## នីតិថ្នាក់នៃប្រធានប៉ុស្តិ៍កុងស៊ុល

១- បណ្តាថ្នាក់នៃប្រធានប៉ុស្តិ៍កុងស៊ុលចែកចេញជា ៤ :

ក- អគ្គកុងស៊ុល

ខ- កុងស៊ុល

គ- កុងស៊ុលរង

ឃ- ភ្នាក់ងារកុងស៊ុល

២- កថាខ័ណ្ឌ ១ នៃប្រការនេះមិនកំរិតនូវសិទ្ធិនៃភាគីណាមួយក្នុងការកំណត់ឈ្មោះអោយមន្ត្រីកុងស៊ុលផ្សេងទៀតក្រៅពីប្រធាននៃប៉ុស្តិ៍កុងស៊ុល ។

## ប្រការ ១០

## ការតែងតាំង និង ការយល់ព្រមទទួលយកបណ្តាប្រធាននៃប៉ុស្តិ៍កុងស៊ុល

១- រដ្ឋដាក់កុងស៊ុលជាអ្នកចាត់តាំងបណ្តាប្រធានប៉ុស្តិ៍កុងស៊ុល ហើយរដ្ឋម្ចាស់ផ្ទះជាអ្នកយល់ព្រមទទួលប្រធានស្ថានកុងស៊ុលបំពេញមុខងាររបស់ខ្លួន ។

២- ដោយស្ថិតក្រោម ខ ទាំងឡាយនៃអនុសញ្ញានេះ បណ្តាបែបបទនៃការចាត់តាំង និងការយល់ព្រម ទទួលប្រធានប៉ុស្តិ៍កុងស៊ុលត្រូវបានកំណត់ដោយច្បាប់ បទបញ្ញា និងទំនៀមទំលាប់រៀងៗខ្លួនរបស់រដ្ឋដាក់កុងស៊ុល និង រដ្ឋម្ចាស់ផ្ទះ ។

## ប្រការ ១១

## លិខិតស្នើតែងតាំង ឬការជូនដំណឹងពីការតែងតាំង

១- ប្រធានប៉ុស្តិ៍កុងស៊ុល ត្រូវបានរដ្ឋដាក់កុងស៊ុលផ្តល់អោយនូវឯកសារមួយមានរូបភាពជាលិខិតស្នើការតែងតាំង ឬ លិខិតុបករណ៍មានតំលៃប្រហាក់ប្រហែលគ្នាដែលធ្វើឡើងសំរាប់ការតែងតាំងនិមួយៗ ដោយបញ្ជាក់ពីឋានៈ និងបង្ហាញពីគោត្តនាម និងនាម ប្រភេទថ្នាក់ មណ្ឌលកុងស៊ុល និងទីតាំងនៃប៉ុស្តិ៍កុងស៊ុល ។

២- រដ្ឋដាក់កុងស៊ុលត្រូវបញ្ជូនលិខិតស្នើការតែងតាំង ឬលិខិតុបករណ៍មានតំលៃប្រហាក់ប្រហែលគ្នាតាមរយៈការទូត ឬ តាមរយៈផ្សេងទៀតដែលសមស្រប ទៅរដ្ឋាភិបាលនៃរដ្ឋដែលប្រធានប៉ុស្តិ៍កុងស៊ុលត្រូវបំពេញមុខងាររបស្ងួន ។

៣- ប្រសិនបើរដ្ឋម្ចាស់ផ្ទះព្រមទទួលជននោះ រដ្ឋដាក់កុងស៊ុលអាចផ្លាស់ប្តូរលិខិតស្នើការតែងតាំង ឬលិខិតមានតំលៃប្រហាក់ប្រហែលគ្នា ជាលិខិតជូនដំណឹងមួយដូចមានចុះការកំណត់ទាំងឡាយដែលចែងក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះ ។

## ប្រការ ១២

## លិខិតឱកាសទាន

១- ប្រធានប៉ុស្តិ៍កុងស៊ុលត្រូវបានទទួលស្គាល់អោយបំពេញមុខងាររបស់ខ្លួន ដោយមានការអនុញ្ញាតិពីរដ្ឋម្ចាស់ផ្ទះ ដែលហៅថា "*លិខិតឱកាសទាន*" ទោះបីការអនុញ្ញាតិនេះមានរូបភាពជាអ្វីក៏ដោយ ។

២- រដ្ឋណាមួយដែលបដិសេធមិនផ្តល់លិខិតឱកាសទាន មិនចាំបាច់ផ្តល់មូលហេតុនៃការបដិសេធនេះ ទៅឱ្យរដ្ឋដាក់កុងស៊ុលទេ ។

៣-ដោយស្ថិតក្រោម ខ ទាំងឡាយនៃប្រការ ១៣ និង ១៥ ប្រធានប៉ុស្តិ៍កុងស៊ុលមិនអាចចូលបំពេញមុខងារមុនបានទទួលលិខិតឱកាសទានឡើយ ។

## ប្រការ ១៣
## ការទទួលស្គាល់ជាបណ្តោះអាសន្ននូវប្រធានប៉ុស្តិ៍កុងស៊ុល

ក្នុងការរង់ចាំការចេញលិខិតឱកាសទាន ប្រធានប៉ុស្តិ៍កុងស៊ុលអាចត្រូវទទួលស្គាល់អោយបំពេញមុខងារជាបណ្តោះអាសន្ន ។ ក្នុងករណីនេះ ខ ទាំងឡាយនៃអនុសញ្ញានេះអាចយកមកអនុវត្តបាន ។

## ប្រការ ១៤
## ការជូនដំណឹងទៅអាជ្ញាធរនៃមណ្ឌលកុងស៊ុល

ចាប់ពីពេលដែលប្រធានប៉ុស្តិ៍កុងស៊ុលត្រូវបានទទួលស្គាល់ឱ្យបំពេញមុខងាររបស់ខ្លួនទោះបីជាបណ្តោះអាសន្នក្តី រដ្ឋម្ចាស់ផ្ទះត្រូវតែជូនដំណឹងជាបន្ទាន់ទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួននូវមណ្ឌលកុងស៊ុល ។ ជាមួយនេះដែរ រដ្ឋម្ចាស់ផ្ទះត្រូវចាត់វិធានការណ៍ចាំបាច់ដើម្បីអោយប្រធានប៉ុស្តិ៍កុងស៊ុលអាចបំពេញភារកិច្ចរបស់ខ្លួនបាន និងទទួលបាននូវការរាប់រកដូចដែលបានចែងក្នុងខទាំងឡាយនៃអនុសញ្ញានេះ ។

## ប្រការ ១៥
## ការបំពេញជាបណ្តោះអាសន្ននូវមុខងាររបស់ប្រធានប៉ុស្តិ៍កុងស៊ុល

១- ប្រសិនបើប្រធានប៉ុស្តិ៍កុងស៊ុលមិនអាចបំពេញមុខងាររបស់ខ្លួនបាន ឬ តំណែងរបស់ខ្លួនត្រូវនៅទំនេរប្រធានស្តីទីម្នាក់អាចធ្វើការងារជាបណ្តោះអាសន្នដូចប្រធានប៉ុស្តិ៍កុងស៊ុល ។

២- គោត្តនាម និងនាម នៃប្រធានស្តីទីត្រូវបានជូនដំណឹងជូនដោយបេសកកម្មទូតនៃរដ្ឋដាក់កុងស៊ុល ហើយប្រសិនបើគ្មានបេសកកម្មទូតនៃរដ្ឋដាក់កុងស៊ុលក្នុងរដ្ឋម្ចាស់ផ្ទះទេ ត្រូវជូនដំណឹងដោយប្រធានប៉ុស្តិ៍កុងស៊ុល ហើយបើប្រធានប៉ុស្តិ៍កុងស៊ុលមិនអាចជូនដំណឹងបាន រាល់អាជ្ញាធរមានសមត្ថកិច្ចណាមួយរបស់រដ្ឋដាក់កុងស៊ុលអាចជូនដំណឹងនេះបានទៅក្រសួងការបរទេសនៃរដ្ឋម្ចាស់ផ្ទះ ឬ ទៅអាជ្ញាធរដែលក្រសួងនេះចាត់តាំងឡើង ។ ជាគោលការណ៍ទូទៅការជូនដំណឹងនេះត្រូវធ្វើជាមុន។

រដ្ឋម្ចាស់ផ្ទះអាចយល់ព្រមទទួលយកប្រធានស្ដីទីនូវជនណាម្នាក់ដែលមិនមែនជាភ្នាក់ងារការទូត និងមិនមែនជាមន្ត្រីកុងស៊ុលនៃរដ្ឋដាក់កុងស៊ុលនៅក្នុងរដ្ឋម្ចាស់ផ្ទះ ។

៣- អាជ្ញាធរសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះត្រូវផ្ដល់ការឧបត្ថម្ភ និងការការពារដល់ប្រធានស្ដីទី ។ ក្នុងរយៈពេលនៃការចាត់ការរបស់ខ្លួន ខ ទាំងឡាយនៃអនុសញ្ញានេះ ត្រូវបានអនុវត្តចំពោះជននោះដូចគ្នានឹងប្រធានប៉ុស្ដិ៍កុងស៊ុលដែរ ។ ក៏ប៉ុន្តែរដ្ឋម្ចាស់ផ្ទះមិនមានការចាំបាច់ត្រូវផ្ដល់ដល់ប្រធានស្ដីទីនោះនូវភាពងាយស្រួល បុព្វសិទ្ធិ ឬអភ័យឯកសិទ្ធិទាំងឡាយដែលប្រធានកុងស៊ុលត្រូវមានឡើយនៅពេលដែលប្រធានកុងស៊ុលស្ដីទីមិនបានបំពេញលក្ខខ័ណ្ឌផ្សេងៗ ។

៤- កាលណាសមាជិកនៃបុគ្គលិកការទូតម្នាក់របស់តំណាងការទូតនៃរដ្ឋដាក់កុងស៊ុលនៅក្នុងរដ្ឋម្ចាស់ផ្ទះត្រូវបានរដ្ឋដាក់កុងស៊ុលតែងតាំងជាប្រធានកុងស៊ុលស្ដីទី តាមលក្ខណៈដែលមានចែងក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះ ជននោះបន្តប្រើប្រាស់នូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិការទូតតទៅប្រសិនបើរដ្ឋម្ចាស់ផ្ទះមិនជំទាស់ ។

## ប្រការ ១៦
## អំពីអាសនានុក្រមរវាងបណ្ដាប្រធានប៉ុស្ដិ៍កុងស៊ុល

១- បណ្ដាប្រធានប៉ុស្ដិ៍កុងស៊ុលត្រូវទទួលលំដាប់ថ្នាក់ក្នុងថ្នាក់និមួយៗទៅតាមកាលបរិច្ឆេទនៃការផ្ដល់លិខិតឱកាសទាន ។

២- ក៏ប៉ុន្តែក្នុងករណីប្រធានប៉ុស្ដិ៍កុងស៊ុលមួយ ត្រូវបានទទួលស្គាល់អោយបំពេញមុខងាររបស់ខ្លួន ជាបណ្ដោះអាសន្ន មុនបានទទួលលិខិតឱកាសទាន ពេលនោះកាលបរិច្ឆេទនៃការទទួលស្គាល់ជាបណ្ដោះអាសន្ននេះកំណត់នូវលំដាប់ថ្នាក់នៃអាសនានុក្រម ។ លំដាប់ថ្នាក់នៃអាសនានុក្រមនេះ ត្រូវបានរក្សាទុក បន្ទាប់ពីការផ្ដល់លិខិតឱកាសទាន ។

៣- លំដាប់ថ្នាក់នៃអាសនានុក្រមរវាងប្រធានប៉ុស្ដិ៍កុងស៊ុល ២ រូប ឬ ច្រើនរូបដែលបានទទួលលិខិតឱកាសទាន ឬ ការទទួលស្គាល់ជាបណ្ដោះអាសន្ននៅថ្ងៃជាមួយគ្នា ត្រូវកំណត់យកតាមកាលបរិច្ឆេទដែលលិខិតស្នើតែងតាំង ឬ លិខិតប្រហាក់ប្រហែលគ្នាកាលបានដាក់ជូន ឬ ដែលការជូនដំណឹងទៅរដ្ឋម្ចាស់ផ្ទះដូចមានចែងក្នុងកថាខ័ណ្ឌ ៣ នៃប្រការ ១១ បានធ្វើ ។

៤- បណ្ដាប្រធានកុងស៊ុលស្ដីទី ត្រូវទទួលលំដាប់ថ្នាក់បន្ទាប់ពីបណ្ដាប្រធានប៉ុស្ដិ៍កុងស៊ុល ។ ប្រធានកុងស៊ុលស្ដីទីទាំងនេះ ត្រូវទទួលលំដាប់ថ្នាក់ទៅតាមកាលបរិច្ឆេទដែលគេបានចូលបំពេញមុខងារជាប្រធានកុងស៊ុលស្ដីទី ហើយដែលកាលបរិច្ឆេទនោះត្រូវបានកំណត់ក្នុងការជូនដំណឹង ដែលបានធ្វើឡើងក្នុងក្របខ័ណ្ឌនៃកថាខ័ណ្ឌ ២ នៃប្រការ ១៥ ។

៥- បណ្តាមន្ត្រីកុងស៊ុលកិត្តិយស ជាប្រធានប៉ុស្តិ៍កុងស៊ុលត្រូវទទួលលំដាប់ថ្នាក់ក្នុងថ្នាក់និមួយៗ បន្ទាប់ពីប្រធានស្ថានកុងស៊ុលអាជីព ទៅតាមរបៀបរបប និងក្បួនច្បាប់ដែលមានចែងក្នុងកថាខ័ណ្ឌខាងដើម ។

៦- បណ្តាប្រធានប៉ុស្តិ៍កុងស៊ុល មានអាសនានុក្រមខ្ពស់ជាងមន្ត្រីកុងស៊ុលទាំងឡាយដែលពុំមានតួនាទីនេះ ។

## ប្រការ ១៧

## ការបំពេញកិច្ចការទូតដោយមន្ត្រីកុងស៊ុល

១- ក្នុងរដ្ឋមួយដែលរដ្ឋដាក់កុងស៊ុលគ្មានបេសកកម្មទូត និងពុំមានបេសកកម្មទូត នៃប្រទេសផ្សេងណាមួយតំណាងអោយទេនោះ មន្ត្រីកុងស៊ុលដោយមានការព្រមព្រៀងពីរដ្ឋម្ចាស់ផ្ទះអាចត្រូវចាត់តាំងអោយបំពេញកិច្ចការការទូតបានដោយគ្មានផលប៉ះពាល់អ្វីដល់លក្ខន្តិកៈកុងស៊ុលរបស់មន្ត្រីនេះទេ ។ ការបំពេញកិច្ចការទាំងនេះ ដោយមន្ត្រីកុងស៊ុលពុំមានផ្តល់សិទ្ធិអោយមន្ត្រីនេះប្រើប្រាស់នូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិការទូតឡើយ ។

២- មន្ត្រីកុងស៊ុលម្នាក់ក្រោយពីបានជូនដំណឹងទៅរដ្ឋម្ចាស់ផ្ទះ អាចត្រូវបានចាត់តាំងឱ្យធ្វើជាអ្នកតំណាងរដ្ឋដាក់កុងស៊ុលអមអង្គការអន្តររដ្ឋាភិបាលណាមួយ ។ ពេលបំពេញការងារក្នុងតួនាទីនេះ មន្ត្រីនេះមានសិទ្ធិទទួលបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិទាំងអស់ដែលច្បាប់ ប្រពៃណីអន្តរជាតិ ឬ កិច្ចព្រមព្រៀងអន្តរជាតិកំណត់ឱ្យអ្នកតំណាងម្នាក់អមអង្គការអន្តររដ្ឋាភិបាល ។ ក៏ប៉ុន្តែ ចំពោះរាល់មុខងារកុងស៊ុលដែលខ្លួនបានបំពេញ ជននោះគ្មានសិទ្ធិទទួលអភ័យឯកសិទ្ធិក្នុងការជំនុំជំរះទូលំទូលាយជាងអភ័យឯកសិទ្ធិដែលមន្ត្រីកុងស៊ុលម្នាក់ទទួលបានក្នុងក្របខ័ណ្ឌនៃអនុសញ្ញានេះទេ ។

## ប្រការ ១៨

## អំពីការតែងតាំងជនដដែលម្នាក់ជាមន្ត្រីកុងស៊ុលសំរាប់រដ្ឋពីរ ឬ រដ្ឋច្រើនទៀត

រដ្ឋពីរ ឬ រដ្ឋច្រើនទៀតអាចចាត់តាំងដោយមានការព្រមព្រៀងពីរដ្ឋម្ចាស់ផ្ទះ នូវជនដដែលម្នាក់ជាមន្ត្រីកុងស៊ុលក្នុងរដ្ឋនេះ ។

## ប្រការ ១៩

## អំពីការតែងតាំងបណ្តាសមាជិកបុគ្គលិកកុងស៊ុល

១- ដោយស្ថិតក្រោមបទបញ្ញត្តិនៃប្រការ ២០-២២- និង ២៣ រដ្ឋដាក់កុងស៊ុលតែងតាំងបានតាមបំណងរបស់ខ្លួន នូវបណ្តាសមាជិកបុគ្គលិកកុងស៊ុល ។

២- រដ្ឋដាក់កុងស៊ុលជូនដំណឹងទៅរដ្ឋម្ចាស់ផ្ទះនូវគោត្តនាម នាម ប្រភេទ និងថ្នាក់របស់មន្ត្រីកុងស៊ុលទាំងអស់ក្រៅពីប្រធានប៉ុស្តិ៍កុងស៊ុលឱ្យបានរយៈពេលមុនយូរសមល្មម ដើម្បីឱ្យរដ្ឋម្ចាស់ផ្ទះអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនដូចមានចែងក្នុងកថាខ័ណ្ឌ ៣ នៃប្រការ ២៣ ប្រសិនបើរដ្ឋនោះមានចំណងនឹងធ្វើបែបនេះ ។

៣- រដ្ឋដាក់កុងស៊ុលអាចស្នើសុំទៅរដ្ឋម្ចាស់ផ្ទះ អោយផ្តល់លិខិតឱកាសទានដល់មន្ត្រីកុងស៊ុលណាម្នាក់ដែលមិនមែនជាប្រធានប៉ុស្តិ៍កុងស៊ុល ប្រសិនបើច្បាប់ និងបទបញ្ជារបស់រដ្ឋខ្លួនតម្រូវអោយធ្វើយ៉ាងនេះ ។

៤- រដ្ឋម្ចាស់ផ្ទះអាចផ្តល់លិខិតឱកាសទានដល់មន្ត្រីកុងស៊ុលណាម្នាក់ ដែលមិនមែនជាប្រធានប៉ុស្តិ៍កុងស៊ុល ប្រសិនបើច្បាប់ និងបទបញ្ញត្តិនៃរដ្ឋខ្លួនតម្រូវអោយធ្វើយ៉ាងនេះ ។

## ប្រការ ២០
## អំពីចំនួនបុគ្គលិកកុងស៊ុល

បើគ្មានកិច្ចព្រមព្រៀងច្បាស់លាស់ស្តីពីចំនួនបុគ្គលិកនៃស្ថានកុងស៊ុលទេ រដ្ឋម្ចាស់ផ្ទះអាចទាមទារអោយចំនួននេះស្ថិតក្នុងក្របខ័ណ្ឌមួយដែលខ្លួនយល់ថាសមហេតុផល និងធម្មតាយោងទៅតាមកាលៈទេសៈ និងលក្ខណៈដែលកើតមានក្នុងមណ្ឌលកុងស៊ុល និង ទៅតាមសេចក្តីត្រូវការនៃប៉ុស្តិ៍កុងស៊ុលនោះ ។

## ប្រការ ២១
## អំពីអាសនានុក្រមរវាងបណ្តាមន្ត្រីកុងស៊ុលនៃប៉ុស្តិ៍កុងស៊ុល

លំដាប់ថ្នាក់នៃអាសនានុក្រមរវាងបណ្តាមន្ត្រីកុងស៊ុលនៃប៉ុស្តិ៍កុងស៊ុលមួយ និងរាល់ការប្រែប្រួលនៃលំដាប់ថ្នាក់នោះ ត្រូវបានជូនដំណឹងតាមបេសកកម្មទូតរបស់រដ្ឋដាក់កុងស៊ុល ឬ បើគ្មានបេសកកម្មទូតនៅក្នុងរដ្ឋម្ចាស់ផ្ទះទេ តាមរយៈប្រធានប៉ុស្តិ៍កុងស៊ុលទៅក្រសួងការបរទេសនៃរដ្ឋម្ចាស់ផ្ទះ ឬ ទៅអាជ្ញាធរដែលចាត់តាំងឡើងដោយក្រសួងនេះ ។

## ប្រការ ២២
## អំពីសញ្ជាតិរបស់បណ្តាមន្ត្រីកុងស៊ុល

១- ជាគោលការណ៍ មន្ត្រីកុងស៊ុលត្រូវមានសញ្ជាតិរបស់រដ្ឋដាក់កុងស៊ុល ។

២- បណ្តាមន្ត្រីកុងស៊ុលពុំអាចត្រូវបានតែងតាំងក្នុងចំណោមបណ្តាពលរដ្ឋនៃរដ្ឋម្ចាស់ផ្ទះបានទេ លើកលែងតែមានការយល់ព្រមជាក់លាក់ពីរដ្ឋនេះ ហើយការយល់ព្រមនេះអាចដកហូតវិញបាន ។

៣- រដ្ឋម្ចាស់ផ្ទះអាចរក្សាសិទ្ធិដដែលខាងលើ ចំពោះអាណិកជននៃរដ្ឋផ្សេងមួយទៀតដែលមិនមែនជាអាណិកជននៃរដ្ឋដាក់កុងស៊ុលផងដែរ ។

## ប្រការ ២៣

## បុគ្គលដែលមិនអាចទទួលយកបាន

១- នៅគ្រប់ពេលវេលា រដ្ឋម្ចាស់ផ្ទះអាចជូនពតិមានទៅរដ្ឋដាក់កុងស៊ុលថា មន្ត្រីកុងស៊ុលម្នាក់មិនអាចទទួលស្គាល់បាន ឬ រាល់សមាជិកបុគ្គលិកកុងស៊ុលដទៃទៀតមិនអាចទទួលយកបាន ។ ពេលនោះរដ្ឋដាក់កុងស៊ុលនឹងហៅជនដែលកើតហេតុនោះមកវិញ ឬ បញ្ចប់មុខងាររបស់ជននោះនៅក្នុងស្ថានកុងស៊ុលទៅតាមករណីជាក់ស្តែង ។

២- ប្រសិនបើរដ្ឋដាក់កុងស៊ុលបដិសេធមិនអនុវត្ត ឬ មិនអនុវត្តក្នុងរយៈពេលមួយដ៏សមរម្យនូវកាតព្វកិច្ចដែលធ្លាក់លើខ្លួនដូចមានចែងក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះ រដ្ឋម្ចាស់ផ្ទះតាមករណីជាក់ស្តែងអាចដកហូតលិខិតឱកាសទានពីជនកើតហេតុនោះ ឬ ឈប់ចាត់ទុកជននោះជាសមាជិកនៃបុគ្គលិកកុងស៊ុល ។

៣- ជនម្នាក់ដែលត្រូវបានចាត់តាំងទៅធ្វើការនៅប៉ុស្តិ៍កុងស៊ុលមួយ អាចត្រូវប្រកាសមិនទទួលយកបានមុនពេលដែលជននោះទៅដល់លើទឹកដីនៃរដ្ឋម្ចាស់ផ្ទះ ឬ ប្រសិនបើជននោះបានចូលទៅដល់រួចហើយមុនពេលដែលជននោះទទួលមុខងារនៅប៉ុស្តិ៍កុងស៊ុលទៅទៀត ក្នុងករណីបែបនេះរដ្ឋដាក់កុងស៊ុល ត្រូវដកការតែងតាំងជននោះមកវិញ ។

៤- ចំពោះករណីដែលបានចែងក្នុងកថាខ័ណ្ឌ ១ និង ៣ នៃប្រការនេះ រដ្ឋម្ចាស់ផ្ទះមិនមានការចាំបាច់ត្រូវជូនដំណឹងទៅរដ្ឋដាក់កុងស៊ុលពីមូលហេតុនៃសេចក្តីសំរេចរបស់ខ្លួនទេ។

## ប្រការ ២៤

## ការជូនដំណឹងទៅរដ្ឋម្ចាស់ផ្ទះពីការតែងតាំង ការមកដល់ និង ការចេញដំណើរ

១- ត្រូវជូនដំណឹងទៅក្រសួងការបរទេសនៃរដ្ឋម្ចាស់ផ្ទះ ឬ ទៅអាជ្ញាធរដែលក្រសួងនេះបានចាត់តាំងនូវ :

ក- ការតែងតាំងនៃបណ្តាសមាជិកនៃប៉ុស្តិ៍កុងស៊ុលមួយ ការមកដល់ ក្រោយការតែងតាំងរបស់ជនទាំងនោះនៅស្ថានកុងស៊ុល ការចេញដំណើរជាស្ថាពររបស់គេ ឬការបញ្ចប់នៃមុខងាររបស់គេ ព្រមទាំងការប្រែប្រួលពាក់ព័ន្ធដល់លក្ខន្តិកៈរបស់គេដែលអាចកើតមានក្នុងកំឡុងពេលដែលជនទាំងនោះបំពេញមុខងាររបស់គេនៅប៉ុស្តិ៍កុងស៊ុល

ខ- ការមកដល់ និងការចេញដំណើរជាស្ថាពររបស់ជនណាម្នាក់ក្នុងគ្រួសារនៃសមាជិកណាម្នាក់នៃបុំស្តិ៍កុងស៊ុលមួយដែលមករស់នៅជាគ្រួសារ និងហេតុការណ៍ដែលជនណាម្នាក់ក្លាយទៅជា ឬឈប់ជាសមាជិករបស់គ្រួសារ

គ- ការមកដល់ និងការចេញដំណើរជាស្ថាពរនៃបណ្តាសមាជិកបុគ្គលិកឯកជន និងការបញ្ចប់នូវមុខងារនៃជនទាំងនោះក្នុងតួនាទីនេះ

ឃ- ការទទួលយកចូលធ្វើការ និង ការបញ្ឈប់ពីមុខងារនូវបណ្តាជនដែលមានទីលំនៅ នៅក្នុងរដ្ឋម្ចាស់ផ្ទះក្នុងនាទីជាសមាជិកនៃបុំស្តិ៍កុងស៊ុល ឬ ក្នុងនាទីជាសមាជិកបុគ្គលិកឯកជនដែលមានសិទ្ធិទទួលបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ ។

២- នៅគ្រប់ពេលវេលាដែលអាចធ្វើទៅបាន ការមកដល់ និងការធ្វើដំណើរចេញជាស្ថាពរ ក៏ត្រូវចាត់ទុកជាកម្មវត្ថុនៃការជូនដំណឹងមួយជាមុនផងដែរ ។

## ផ្នែក ២

## ការបញ្ចប់នៃមុខងារកុងស៊ុល

### ប្រការ ២៥

### ការបញ្ចប់នៃមុខងាររបស់សមាជិកម្នាក់នៃបុំស្តិ៍កុងស៊ុល

បណ្តាមុខងារនៃសមាជិកម្នាក់នៃបុំស្តិ៍កុងស៊ុលត្រូវបានបញ្ចប់ជាអាទិ៍ដោយ :

ក-ការជូនដំណឹងពីរដ្ឋដាក់កុងស៊ុលទៅរដ្ឋម្ចាស់ផ្ទះ ដោយបញ្ជាក់ថាមុខងាររបស់ជននោះត្រូវបានបញ្ចប់

ខ- ការដកហូតលិខិតឱកាសទាន

គ- ការជូនដំណឹងពីរដ្ឋម្ចាស់ផ្ទះទៅរដ្ឋដាក់កុងស៊ុលពីការជំរាបថា ខ្លួនឈប់ទទួលស្គាល់ជននោះ ជាសមាជិកបុគ្គលិកកុងស៊ុលតទៅទៀតហើយ ។

### ប្រការ ២៦

### ការចាកចេញពីទឹកដីនៃរដ្ឋម្ចាស់ផ្ទះ

ទោះបីក្នុងករណីមានវិវាទដោយអាវុធក៏ដោយ រដ្ឋម្ចាស់ផ្ទះត្រូវតែទុកពេលវេលា និងបង្កភាពងាយស្រួលចាំបាច់អោយបណ្តាសមាជិកនៃបុំស្តិ៍កុងស៊ុល និងបណ្តាសមាជិកបុគ្គលិកឯកជន ក្រៅពីពលរដ្ឋនៃរដ្ឋម្ចាស់ផ្ទះ ក៏ដូចជាបណ្តាសមាជិកគ្រួសាររបស់គេដែលរស់នៅជាមួយ ទោះបីមានសញ្ជាតិណាក៏ដោយ ដើម្បីរៀបចំការចេញដំណើរ និងចាកចេញពីទឹកដីនៃរដ្ឋខ្លួនក្នុងរយៈពេលដ៏ឆាប់បំផុតក្រោយពីបញ្ឈប់នូវមុខងាររបស់គេ ។

ជាពិសេសប្រសិនបើមានសេចក្តីត្រូវការ រដ្ឋម្ចាស់ផ្ទះត្រូវផ្តល់អោយគេនូវមធ្យោបាយដឹកជញ្ជូនចាំបាច់សំរាប់គេទាំងនេះធ្វើដំណើរ និងសំរាប់ដឹកទ្រព្យសម្បត្តិរបស់គេ លើកលែងតែទ្រព្យសម្បត្តិរកបានក្នុងរដ្ឋម្ចាស់ផ្ទះ ដែលការនាំចេញត្រូវហាមឃាត់នៅពេលចេញដំណើរនោះ ។

## ប្រការ ២៧

## ការការពារទីស្ថាន និងបណ្ណប័ណ្ណសារកុងស៊ុល និង ផលប្រយោជន៍នៃរដ្ឋដាក់កុងស៊ុលក្នុងកាលៈទេសៈពិសេស

១- ក្នុងករណីមានការផ្តាច់ទំនាក់ទំនងកុងស៊ុលរវាងរដ្ឋពីរ :

ក- រដ្ឋម្ចាស់ផ្ទះមានការចាំបាច់ត្រូវគោរព និង ការពារទីស្ថានកុងស៊ុល ក៏ដូចជាទ្រព្យសម្បត្តិនៃប៉ុស្តិ៍កុងស៊ុល និងបណ្ណប័ណ្ណសារកុងស៊ុល ទោះបីក្នុងករណីមានវិវាទដោយអាវុធក៏ដោយ

ខ- រដ្ឋដាក់កុងស៊ុលអាចប្រគល់ការថែរក្សាបណ្តាទីស្ថានកុងស៊ុល ព្រមទាំងទ្រព្យសម្បត្តិដែលមានទីនោះ និងបណ្ណប័ណ្ណសារកុងស៊ុលទៅរដ្ឋផ្សេងមួយទៀតដោយមានការព្រមព្រៀងពីរដ្ឋម្ចាស់ផ្ទះ

គ- រដ្ឋដាក់កុងស៊ុលអាចប្រគល់ការការពារផលប្រយោជន៍របស់ខ្លួន និងផលប្រយោជន៍របស់អាណិកជនខ្លួនទៅរដ្ឋផ្សេងមួយទៀត ដោយមានការព្រមព្រៀងពីរដ្ឋម្ចាស់ផ្ទះ ។

២- ក្នុងករណីមានការបិទជាបណ្តោះអាសន្ន ឬ ជាស្ថាពរនៃប៉ុស្តិ៍កុងស៊ុលមួយ ខ នៃអនុកថាខ័ណ្ឌ ក ក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះ អាចយកមកអនុវត្តបាន ។ ម្យ៉ាងទៀត :

ក- កាលបើរដ្ឋដាក់កុងស៊ុល ថ្វីបើពុំមានតំណាងដោយបេសកកម្មទូតនៅក្នុងរដ្ឋម្ចាស់ផ្ទះក៏ដោយមានប៉ុស្តិ៍កុងស៊ុលមួយផ្សេងទៀតនៅលើទឹកដីនៃរដ្ឋម្ចាស់ផ្ទះ ប៉ុស្តិ៍កុងស៊ុលនេះដោយមានការយល់ព្រមពីរដ្ឋម្ចាស់ផ្ទះ អាចត្រូវចាត់អោយទទួលបន្ទុកថែរក្សាទីស្ថាននៃប៉ុស្តិ៍កុងស៊ុលដែលត្រូវបិទទ្រព្យសម្បត្តិដែលស្ថិត នៅទីនោះ និងប័ណ្ណសារកុងស៊ុល ព្រមទាំងបំពេញមុខងារកុងស៊ុលក្នុងមណ្ឌលកុងស៊ុលដែលបិទ ឬ

ខ- កាលណារដ្ឋដាក់កុងស៊ុលពុំមានបេសកកម្មទូត ឬ ប៉ុស្តិ៍កុងស៊ុលផ្សេងទៀតក្នុងរដ្ឋម្ចាស់ផ្ទះទេនោះ ខ ក្នុងអនុកថាខ័ណ្ឌ ខ និង គ នៃកថាខ័ណ្ឌ ១ នៃប្រការនេះអាចយកមកអនុវត្តបាន ។

## ជំពូក II

## ភាពងាយស្រួល បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិពាក់ព័ន្ធដល់បណ្តាប៉ុស្តិ៍កុងស៊ុល បណ្តាមន្ត្រីកុងស៊ុលអាជីព និង បណ្តាសមាជិកដទៃទៀតនៃប៉ុស្តិ៍កុងស៊ុលមួយ

### ផ្នែក ១ : ភាពងាយស្រួល បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិពាក់ព័ន្ធដល់ ប៉ុស្តិ៍កុងស៊ុល

## ប្រការ ២៨

### ភាពងាយស្រួលដែលត្រូវបានផ្តល់អោយប៉ុស្តិ៍កុងស៊ុលសំរាប់ធ្វើសកម្មភាព

រដ្ឋម្ចាស់ផ្ទះផ្តល់បណ្តាភាពងាយស្រួលដើម្បីការបំពេញមុខងាររបស់ប៉ុស្តិ៍កុងស៊ុល ។

## ប្រការ ២៩

### ការប្រើប្រាស់ទង់ជាតិ និងសញ្ញាជាតិ

១- រដ្ឋដាក់កុងស៊ុលមានសិទ្ធិប្រើប្រាស់ទង់ជាតិ និងសញ្ញាជាតិរបស់រដ្ឋខ្លួនក្នុងរដ្ឋម្ចាស់ផ្ទះ ដោយអនុលោមតាមខនៃប្រការនេះ ។

២- ទង់ជាតិនៃរដ្ឋដាក់កុងស៊ុល អាចបង្ហូត និងសញ្ញាជាតិរបស់រដ្ឋដាក់កុងស៊ុលអាចដាក់លើអាគារដែលជាទីតាំងនៃប៉ុស្តិ៍កុងស៊ុល និង លើក្លោងទ្វារចូល ព្រមទាំងលើលំនៅឋាននៃប្រធានប៉ុស្តិ៍កុងស៊ុល និងលើយានជំនិះរបស់ប្រធានប៉ុស្តិ៍កុងស៊ុល កាលណាយានទាំងនេះ ត្រូវបាប្រើប្រាស់ជាផ្លូវការ ។

៣- ក្នុងការប្រើប្រាស់សិទ្ធិ ដែលអនុញ្ញាតដោយប្រការនេះ គេនឹងត្រូវគិតដល់បណ្តាច្បាប់ បទបញ្ញត្តិ និងទំលាប់របស់រដ្ឋម្ចាស់ផ្ទះ ។

## ប្រការ ៣០

### អំពីលំនៅឋាន

១- ក្នុងក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិរបស់ខ្លួន រដ្ឋម្ចាស់ផ្ទះត្រូវសំរួលដល់រដ្ឋដាក់កុងស៊ុលក្នុងការរកលំនៅឋានចាំបាច់សំរាប់ប៉ុស្តិ៍កុងស៊ុលនៅលើទឹកដីរបស់ខ្លួន ឬ ជួយរដ្ឋដាក់កុងស៊ុល ដើម្បីរកលំនៅឋានដោយវិធីណាមួយផ្សេងទៀត ។

២- រដ្ឋម្ចាស់ផ្ទះត្រូវជួយប៉ុស្តិ៍កុងស៊ុលផងដែរ ដើម្បីរកទីលំនៅសមស្របសំរាប់សមាជិករបស់ខ្លួនប្រសិនបើមានសេចក្តីត្រូវការ ។

## ប្រការ ៣១

### សិទ្ធិមិនត្រូវបានគេបំពារបំពាននៃបណ្តាប៉ុស្តិ៍កុងស៊ុល

១- បណ្តាទីឋានកុងស៊ុលមិនត្រូវគេបំពារបំពានបានក្នុងបែបបទដែលបានចែងក្នុងប្រការនេះ ។

២- អាជ្ញាធរនៃរដ្ឋម្ចាស់ផ្ទះ មិនអាចចូលទៅក្នុងភាគណាមួយនៃទីប៉ុស្តិ៍កុងស៊ុល ដែលប៉ុស្តិ៍កុងស៊ុល ប្រើប្រាស់ដាច់មុខសំរាប់ការងាររបស់ខ្លួនឡើយ លើកលែងតែមានការយល់ព្រមពីប្រធានប៉ុស្តិ៍កុងស៊ុល ឬពីជន ដែលប្រធានប៉ុស្តិ៍កុងស៊ុលបានចាត់តាំង ឬ ពីប្រធានបេសកកម្មទូតនៃរដ្ឋដាក់កុងស៊ុល ។ ក៏ប៉ុន្តែការ យល់ព្រមពីប្រធានប៉ុស្តិ៍កុងស៊ុលអាចត្រូវសន្មត់ថាបានទទួលក្នុងករណីមានអគ្គីភ័យ ឬ មហន្តរាយផ្សេងទៀត ដែលតំរូវអោយមានវិធានការណ៍ការពារជាបន្ទាន់ ។

៣- ដោយស្ថិតនៅក្រោម ខ ទាំងឡាយក្នុងកថាខ័ណ្ឌ ២ នៃប្រការនេះ រដ្ឋម្ចាស់ផ្ទះមានកាតព្វកិច្ច ពិសេសក្នុងការចាត់គ្រប់វិធានការណ៍សមស្រប ដើម្បីការពារទីស្ថានកុងស៊ុលកុំអោយមានគេលុកលុយឬធ្វើ អោយខូចខាតនិងដើម្បីកុំឱ្យភាពសុខសាន្តរបស់ប៉ុស្តិ៍កុងស៊ុលត្រូវរំលូកកករ ឬ ក៏ភាពថ្លៃថ្នូររបស់ប៉ុស្តិ៍កុងស៊ុល ត្រូវអាប់អោន ។

៤- បណ្តាទីប៉ុស្តិ៍កុងស៊ុលគ្រឿងសង្ហារឹម និងទ្រព្យសម្បត្តិនៃប៉ុស្តិ៍កុងស៊ុល ក៏ដូចជាមធ្យោបាយដឹក ជញ្ជូនរបស់ប៉ុស្តិ៍កុងស៊ុល មិនអាចធ្វើជាកម្មវត្ថុនៃកំណែនសំរាប់កិច្ចការពារជាតិ ឬ ការប្រើប្រាស់ជាសាធារណៈ តាមរូបភាពណាមួយឡើយ ។ បើសិនជាចាំបាច់ត្រូវមានការដកហូតទ្រព្យសម្បត្តិសំរាប់គោលបំណងនេះ គេ ត្រូវចាត់វិធានការសមស្រប ដើម្បីជៀសវាងកុំអោយមានឧបសគ្គដល់ការបំពេញមុខងារកុងស៊ុល ហើយប្រាក់ សំណង នឹងត្រូវបានប្រគល់ជូនទៅរដ្ឋដាក់កុងស៊ុលវិញឱ្យបានរួសរាន់ និងគ្រប់គ្រាន់ ។

## ប្រការ ៣២
## ការរួចផុតពីសារពើពន្ធនៃបណ្តាទីប៉ុស្តិ៍កុងស៊ុល

១- បណ្តាទីប៉ុស្តិ៍កុងស៊ុល និង លំនៅឋាននៃប្រធានប៉ុស្តិ៍កុងស៊ុលអាជីពដែលរដ្ឋដាក់កុងស៊ុល ឬ រាល់ ជនដែលបំពេញការងារក្នុងផលប្រយោជន៍របស់រដ្ឋនេះ ត្រូវជាម្ចាស់កម្មសិទ្ធិ ឬ ជាអ្នកជួលត្រូវបានរួចផុតពី បណ្តាពន្ធ និងអាករគ្រប់ប្រភេទ មានពន្ធអាករជាតិ តំបន់ ឬ ឃុំ ដរាបណាពុំមែនជាអាករដែលដកហូតជា កំរៃសំរាប់សេវាកម្មឯកជន ។

២- ការរួចផុតពីសារពើពន្ធចែងក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះ មិនអនុវត្តចំពោះពន្ធ និង អាករទាំង នេះទេ កាលណាយោងតាមច្បាប់ និងបទបញ្ញត្តិរបស់រដ្ឋម្ចាស់ផ្ទះ ពន្ធអាករទាំងនោះ ជាបន្ទុករបស់ជនដែល បានចុះកិច្ចសន្យាជាមួយរដ្ឋដាក់កុងស៊ុល ឬ ជាមួយជនដែលបំពេញការងារក្នុងផលប្រយោជន៍របស់រដ្ឋនេះ ។

## ប្រការ ៣៣

## សិទ្ធិមិនត្រូវគេបំពារបំពាននៃបណ្ណាប័ណ្ណសារដ្ឋាន និង បណ្ណាឯកសារកុងស៊ុល

បណ្ណាប័ណ្ណសារដ្ឋាន និងបណ្ណាឯកសារកុងស៊ុល មិនត្រូវជនណាបំពារបំពានបានឡើយ ទោះនៅពេលណានិងក្នុងទីណាក៏ដោយ ។

## ប្រការ ៣៤

## សេរីភាពក្នុងការធ្វើដំណើរ

រដ្ឋម្ចាស់ផ្ទះធានាទូវសេរីភាពក្នុងការធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ និងការធ្វើចរាចររបស់បណ្ណាសមាជិកនៃប៉ុស្តិ៍កុងស៊ុលនៅលើទឹកដីរបស់ខ្លួន លើកលែងតែមានច្បាប់ និងបទបញ្ញត្តិរបស់ខ្លួនស្តីពីការហាមឃាត់មិនឱ្យចូលតំបន់ណាមួយដោយមូលហេតុសន្តិសុខជាតិ ។

## ប្រការ ៣៥

## សេរីភាពក្នុងការទាក់ទង

១- រដ្ឋម្ចាស់ផ្ទះអនុញ្ញាត និងការពារសេរីភាពក្នុងការទាក់ទងរបស់ប៉ុស្តិ៍កុងស៊ុលសំរាប់រាល់សេចក្តីត្រូវការជាផ្លូវការ ។ ក្នុងការទាក់ទងជាមួយរដ្ឋាភិបាលបណ្ណាបេសកកម្មទូត និងប៉ុស្តិ៍កុងស៊ុលដទៃទៀតនៃរដ្ឋដាក់កុងស៊ុល ទោះស្ថិតនៅទីណាក៏ដោយ ប៉ុស្តិ៍កុងស៊ុលអាចប្រើប្រាស់គ្រប់មធ្យោបាយសមស្របទាំងអស់ រួមទាំងហាវីទូត ឬ កុងស៊ុល ហិបទូត ឬ ហិបកុងស៊ុល និងបណ្ណាសារសំងាត់ ឬ លេខសំងាត់ ។ ក៏ប៉ុន្តែប៉ុស្តិ៍កុងស៊ុលអាចតាំងតំលើង និងប្រើប្រាស់ប៉ុស្តិ៍វិទ្យុបាន លុះត្រាតែមានការព្រមព្រៀងពីរដ្ឋម្ចាស់ផ្ទះ ។

២- លិខិតឆ្លើយឆ្លងជាផ្លូវការរបស់ប៉ុស្តិ៍កុងស៊ុល មិនអាចត្រូវបំពារបំពានបានឡើយ ។ ពាក្យថា លិខិតឆ្លើយឆ្លងជាផ្លូវការ គឺរាល់លិខិតឆ្លើយឆ្លងទាក់ទងដល់ប៉ុស្តិ៍កុងស៊ុល និងបណ្ណាមុខងាររបស់ប៉ុស្តិ៍កុងស៊ុល ។

៣- ហិបកុងស៊ុលមិនត្រូវបានគេបើក ឬ ឃាត់ទុកឡើយ ។ ក៏ប៉ុន្តែប្រសិនបើបណ្ណាអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋម្ចាស់ផ្ទះមានមូលហេតុច្បាស់លាស់ជឿជាក់ថា ហិបនោះមានវត្ថុផ្សេងក្រៅពីលិខិតឆ្លើយឆ្លង-ឯកសារ និង វត្ថុផ្សេងៗដែលមានចែងក្នុងកថាខ័ណ្ឌ ៤ នៃប្រការនេះ អាជ្ញាធរនៃរដ្ឋម្ចាស់ផ្ទះអាចស្នើអោយតំណាងម្នាក់នៃរដ្ឋដាក់កុងស៊ុលបើកហិបនោះនៅចំពោះមុខខ្លួន ។ ប្រសិនបើអាជ្ញាធរនៃរដ្ឋដាក់កុងស៊ុលមិនយល់ព្រមតាមពាក្យស្នើសុំទេ ហិបនោះត្រូវផ្ញើត្រលប់ទៅកន្លែងដើមរបស់វាវិញ ។

៤- បណ្តាកញ្ចប់ផ្ញើបានជាហិបកុងស៊ុល ត្រូវដាក់សញ្ញាខាងក្រៅច្បាស់លាស់ បញ្ជាក់ពី លក្ខណៈជាហិបកុងស៊ុល ហើយអាចដាក់បានតែលិខិតឆ្លើយឆ្លងជាផ្លូវការ ក៏ដូចជាឯកសារ ឬ វត្ថុសំរាប់ប្រើប្រាស់ជាផ្លូវការតែប៉ុណ្ណោះ ។

៥- ហាវីកុងស៊ុលត្រូវមានកាន់ឯកសារជាផ្លូវការបញ្ជាក់ពីលក្ខណៈរបស់ខ្លួន និង បញ្ជាក់ពីចំនួនកញ្ចប់ដែលរួមផ្សំបានជាហិបកុងស៊ុល ។ លើកលែងតែរដ្ឋម្ចាស់ផ្ទះបានព្រមព្រៀង និង លើកលែងតែជននោះជាអាណិកជននៃរដ្ឋដាក់កុងស៊ុល ហាវីកុងស៊ុលមិនអាចត្រូវចាត់តាំងក្នុងចំណោមពលរដ្ឋនៃរដ្ឋម្ចាស់ផ្ទះ ឬ ជនដែលស្នាក់នៅ ជាអចិន្ត្រៃយ៍ក្នុងរដ្ឋម្ចាស់ផ្ទះទេ ។ ក្នុងការបំពេញមុខងាររបស់ហាវីកុងស៊ុលនេះ ត្រូវបានទទួលការការពារពីរដ្ឋម្ចាស់ផ្ទះ ។ ជននេះទទួលបាននូវសិទ្ធិមិនត្រូវបានគេបំពារបំពានលើរូបកាយ និង មិនត្រូវស្ថិតក្រោមរូបភាពនៃការចាប់ ឬឃុំខ្លួនណាមួយទេ ។

៦- រដ្ឋដាក់កុងស៊ុល បេសកកម្មទូត និង ប៉ុស្តិ៍កុងស៊ុលរបស់រដ្ឋនេះ អាចចាត់តាំងហាវីកុងស៊ុលបណ្តោះអាសន្ន ។ ក្នុងករណីនេះ ខ ទាំងឡាយក្នុងកថាខ័ណ្ឌ ៥ នៃប្រការនេះត្រូវអនុវត្តផងដែរចំពោះជននេះ ដោយឡែកតែអភ័យឯកសិទ្ធិដែលបានចែងក្នុងនោះនឹងត្រូវឈប់អនុវត្ត ចាប់ពីពេលជននោះបានប្រគល់នូវហិបកុងស៊ុល ដែលខ្លួនទទួលបន្ទុកនោះ ទៅដល់អ្នកទទួលរួចហើយ ។

៧- ហិបកុងស៊ុលអាចប្រគល់អោយបញ្ជាការនៃនាវា ឬ អាកាសយានពាណិជ្ជកម្មណាមួយដែលត្រូវទៅដល់ចំណុចច្រកចូលដែលមានការអនុញ្ញាត បញ្ជាការនេះត្រូវមានកាន់ឯកសារជាផ្លូវការមួយដែលបញ្ជាក់ពីចំនួនកញ្ចប់ដែលរួមផ្សំបានជាហិប ក៏ប៉ុន្តែជននោះមិនត្រូវបានចាត់ទុកជាហាវីកុងស៊ុលទេ ។ ក្រោយពីមានការស្រុះស្រួលជាមួយបណ្តាអាជ្ញាធរសមត្ថកិច្ចមូលដ្ឋាន ស្ថានកុងស៊ុលអាចបញ្ជូនសមាជិកម្នាក់ក្នុងបណ្តាសមាជិករបស់ខ្លួនទៅទទួលយកហិបនោះដោយផ្ទាល់ និង ដោយសេរីពីបញ្ជាការនាវា ឬ បញ្ជាការយន្តហោះនោះ ។

## ប្រការ ៣៦

## ការទាក់ទងជាមួយបណ្តាអាណិកជននៃរដ្ឋដាក់កុងស៊ុល

១- ដើម្បីអោយការបំពេញមុខងារកុងស៊ុលដែលពាក់ព័ន្ធដល់បណ្តាអាណិកជននៃរដ្ឋដាក់កុងស៊ុលអាចប្រព្រឹត្តិទៅបានដោយងាយស្រួល :

ក- បណ្តាមន្ត្រីកុងស៊ុលត្រូវមានសេរីភាពក្នុងការទាក់ទងជាមួយបណ្តាអាណិកជននៃរដ្ឋដាក់កុងស៊ុល និងជួបប្រាស្រ័យជាមួយជនទាំងនោះ ។ បណ្តាអាណិកជននៃរដ្ឋដាក់កុងស៊ុលក៏ត្រូវមានសេរីភាពដូចគ្នាក្នុងការទាក់ទង និងជួបប្រាស្រ័យជាមួយបណ្តាមន្ត្រីកុងស៊ុល ។

ខ- ប្រសិនបើសាម៉ីជនស្នើសុំ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋម្ចាស់ផ្ទះ ត្រូវជូនពតិមានជាបន្ទាន់ទៅប៉ុស្តិ៍កុងស៊ុលនៃរដ្ឋដាក់កុងស៊ុល កាលណានៅក្នុងមណ្ឌលកុងស៊ុលមានអាណិកជនរបស់ខ្លួន ត្រូវចាប់ខ្លួន ឬត្រូវជាប់ពន្ធនាគារ ឬត្រូវឃុំខ្លួនបណ្តោះអាសន្នរង់ចាំការកាត់ទោស ឬរាល់រូបភាពផ្សេងទៀតនៃការឃុំខ្លួន ។ រាល់ការទាក់ទងជនត្រូវចាប់ខ្លួន ជនជាប់ក្នុងពន្ធនាគារ ឬជនឃុំខ្លួនបណ្តោះអាសន្ន ឬជនឃុំខ្លួនតាមរូបភាពផ្សេងទៀត អាជ្ញាធរខាងលើនេះត្រូវទំនាក់ទំនងជាបន្ទាន់ដែរមកប៉ុស្តិ៍កុងស៊ុល ។ បណ្តាអាជ្ញាធរនៃរដ្ឋម្ចាស់ផ្ទះក៏ត្រូវផ្តល់ពតិមានជាបន្ទាន់ដល់សាម៉ីជន អំពីសិទ្ធិរបស់គេដែលមានចែងក្នុងអនុកឋាខណ្ឌនេះ ។

គ- មន្ត្រីកុងស៊ុលមានសិទ្ធិទៅជួបប្រាស្រ័យជាមួយអាណិកជនណាម្នាក់នៃរដ្ឋដាក់កុងស៊ុល ដែលកំពុងជាប់ក្នុងពន្ធនាគារ កំពុងត្រូវជាប់ឃុំបណ្តោះអាសន្ន ឬកំពុងជាប់ឃុំឃាំង ដើម្បីប្រាស្រ័យជាមួយ ឬឆ្លើយឆ្លងលិខិតស្នាមជាមួយពួកគេ និងដើម្បីរៀបចំឱ្យមានតំណាងស្របច្បាប់របស់ពួកគេ ។ មន្ត្រីកុងស៊ុលក៏មានសិទ្ធិទៅជួបប្រាស្រ័យជាមួយអាណិកជនណាមួយនៃរដ្ឋដាក់កុងស៊ុល ដែលកំពុងជាប់ក្នុងពន្ធនាគារ ឬ កំពុងត្រូវឃុំខ្លួនបណ្តោះអាសន្នក្នុងមណ្ឌលរបស់ខ្លួន តាមការអនុវត្តសាលក្រមមួយ ។ ក៏ប៉ុន្តែមន្ត្រីកុងស៊ុលត្រូវជៀសវាងមិនធ្វើអន្តរាគមន៍ក្នុងផលប្រយោជន៍របស់អាណិកជនណាម្នាក់ ដែលត្រូវជាប់ពន្ធនាគារ ឬ ត្រូវឃុំខ្លួនជាបណ្តោះអាសន្ន ប្រសិនសាម៉ីជននោះជំទាស់យ៉ាងជាក់លាក់មិនព្រមអោយធ្វើ ។

២- សិទ្ធិដែលមានចែងក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះ ត្រូវអនុវត្តឱ្យស្របទៅតាមក្នុងក្របខ័ណ្ឌច្បាប់ និង បទបញ្ញត្តិទាំងឡាយរបស់រដ្ឋម្ចាស់ផ្ទះ ក៏ប៉ុន្តែច្បាប់ និងបទបញ្ញត្តិទាំងឡាយនោះ ត្រូវអនុវត្តឱ្យបានសំរេចនូវគោលបំណងនៃសិទ្ធិដែលបានចែងក្នុងប្រការនេះ ។

## ប្រការ ៣៧

## អំពីពតិមានក្នុងករណីដែលមានមរណភាពអាណាព្យាបាល ភាពតាមវិធីតំណាង ឬអាណាព្យាបាលភាពតាមវិធីឧបត្ថម្ភ ឬគ្រោះថ្នាក់នាវា និងគ្រោះថ្នាក់តាមផ្លូវអាកាស

ប្រសិនបើបណ្តាអាជ្ញាធរមានសមត្ថកិច្ច នៃរដ្ឋម្ចាស់ផ្ទះទទួលបានពតិមានដែលពាក់ព័ន្ធបញ្ហាខាងលើ អាជ្ញាធរទាំងនោះមានភារៈកិច្ច :

ក- ក្នុងករណីមានមរណៈភាពនៃអាណិកជនណាម្នាក់នៃរដ្ឋដាក់កុងស៊ុលត្រូវជំរាបជូនពតិមានជាបន្ទាន់ទៅប៉ុស្តិ៍កុងស៊ុលក្នុងមណ្ឌលដែលមានកើតឡើងនូវមរណភាពនោះ ។

ខ- ជូនដំណឹងជាបន្ទាន់ដល់ប៉ុស្តិ៍កុងស៊ុល ដែលមានសមត្ថកិច្ចនូវរាល់ករណីដែលមានការចាត់តាំងអាណាព្យាបាលណាម្នាក់ ឬ អ្នកឧបត្ថម្ភណាម្នាក់ដែលធ្វើឡើងដើម្បីជាផលប្រយោជន៍របស់អនីតិជនណាម្នាក់ ឬ អាណិកជនជាអសមត្ថជននៃរដ្ឋដាក់កុងស៊ុល ។ ក៏ប៉ុន្តែ ការអនុវត្តច្បាប់ និងបទបញ្ញត្តិទាំងឡាយរបស់រដ្ឋម្ចាស់ផ្ទះនៅតែរក្សាទុកដដែលចំពោះការចាត់តាំងអ្នកអាណាព្យាបាល ឬ អ្នកឧបត្ថម្ភនេះ ។

គ- ជូនដំណឹងជាបន្ទាន់ដល់ប៉ុស្តិ៍កុងស៊ុលដែលនៅជិតជាងគេនិងទីកន្លែងដែលមានកើតគ្រោះថ្នាក់ កាលណាមាននាវាមួយ ឬ កប៉ាល់មួយមានសញ្ជាតិរបស់រដ្ឋដាក់កុងស៊ុលលង់លិច ឬ កឿងក្នុងដែនសមុទ្រ ឬ ក្នុងដែនទឹកផ្ទៃក្នុងនៃរដ្ឋម្ចាស់ផ្ទះ ឬ កាលណាមានអាកាសយានមួយដែលមានចុះលេខក្នុងរដ្ឋដាក់កុងស៊ុលទទួលគ្រោះថ្នាក់លើដែនដីនៃរដ្ឋម្ចាស់ផ្ទះ ។

## មាត្រា ៣៨

## ការទាក់ទងជាមួយអាជ្ញាធរនៃរដ្ឋម្ចាស់ផ្ទះ

ក្នុងការបំពេញមុខងាររបស់ខ្លួន មន្ត្រីកុងស៊ុលអាចទំនាក់ទំនងជាមួយ :

១- អាជ្ញាធរមានសមត្ថកិច្ចមូលដ្ឋាននៃមណ្ឌលកុងស៊ុលរបស់ខ្លួន

២- អាជ្ញាធរកណ្តាលនៃរដ្ឋម្ចាស់ផ្ទះ ប្រសិនបើត្រូវបានអនុញ្ញាតដោយច្បាប់ បទបញ្ញត្តិ និងទំលាប់នៃរដ្ឋម្ចាស់ផ្ទះ ឬដោយកិច្ចព្រមព្រៀងអន្តរជាតិដែលពាក់ព័ន្ធនានា ។

## មាត្រា ៣៩

## អំពីពន្ធ និង អាករ

១- ប៉ុស្តិ៍កុងស៊ុលអាចដកហូតនៅលើទឹកដីនៃរដ្ឋម្ចាស់ផ្ទះនូវពន្ធ និងអាករដែលច្បាប់ និង បទបញ្ញត្តិនៃរដ្ឋដាក់កុងស៊ុលកំណត់ចំពោះលិខិតស្នាមកុងស៊ុល ។

២- ចំនួនទឹកប្រាក់ដែលបានដកហូតជាពន្ធ និងអាករដូចចែងក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះ និងបណ្តាលិខិតបង្កាន់ដៃនៃពន្ធអាករទាំងនោះ ត្រូវបានរួចពីពន្ធ និងអាករទាំងអស់ក្នុងរដ្ឋម្ចាស់ផ្ទះ ។

## ផ្នែក ២ : ភាពងាយស្រួល បុព្វសិទ្ធិ និង អភ័យឯកសិទ្ធិ របស់មន្ត្រីកុងស៊ុល និងសមាជិកដទៃទៀតនៃប៉ុស្តិ៍កុងស៊ុល

## មាត្រា ៤០

## ការគោរពមន្ត្រីកុងស៊ុល

រដ្ឋម្ចាស់ផ្ទះត្រូវរាប់រកមន្ត្រីកុងស៊ុលដោយការគោរព និងត្រូវចាត់រាល់វិធានការសមស្រប ដើម្បីទប់ស្កាត់រាល់ការប៉ះពាល់ដល់រូបកាយ ដល់សេរីភាព និងសេចក្តីថ្លៃថ្នូររបស់ជនទាំងនោះ ។

## ប្រការ ៤១

## សិទ្ធិមិនត្រូវគេបំពារបំពានមន្ត្រីកុងស៊ុល

១- មន្ត្រីកុងស៊ុលមិនអាចត្រូវចាប់ខ្លួន ឬ ឃុំខ្លួនបណ្តោះអាសន្នរង់ចាំការកាត់ទោសបានឡើយ លើកលែងតែមានបទឧក្រិដ្ឋធ្ងន់ធ្ងរ និងបន្ទាប់ពីមានសេចក្តីសំរេចណាមួយពីអាជ្ញាធរមានសមត្ថកិច្ចតុលាការ ។

២- លើកលែងតែករណីដូចចែងក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះមន្ត្រីកុងស៊ុលមិនអាចត្រូវជាប់ពន្ធនាគារ ឬ នៅក្រោមរូបភាពណាមួយផ្សេងទៀតនៃការរឹតត្បិតសេរីភាពផ្ទាល់ខ្លួនរបស់គេបានឡើយ លើកលែងតែមានការអនុវត្តនូវសេចក្តីសំរេចជាស្ថាពររបស់តុលាការ ។

៣- កាលណាមានបណ្តឹងព្រហ្មទណ្ឌ ត្រូវដាក់ប្តឹងចោទប្រកាន់ចំពោះមុខមន្ត្រីកុងស៊ុលណាម្នាក់ មន្ត្រីនោះត្រូវតែចូលបង្ហាញខ្លួននៅចំពោះមុខអាជ្ញាធរសមត្ថកិច្ច ។ ក៏ប៉ុន្តែបណ្តឹងនោះត្រូវធ្វើដោយការគោរពដោយសារតួនាទីជាផ្លូវការរបស់មន្ត្រីនោះ និងធ្វើឱ្យរំខានតិចបំផុតដល់ការបំពេញមុខងារកុងស៊ុល លើកលែងតែករណីដូចចែងក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះ ។ ចំពោះបញ្ហាដែលចែងក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះ ប្រសិនបើមានការចាំបាច់ត្រូវឃុំខ្លួនមន្ត្រីកុងស៊ុលណាម្នាក់ ការប្តឹងចោទប្រកាន់ចំពោះមន្ត្រីនោះត្រូវធ្វើក្នុងរយៈពេលដ៏ខ្លីបំផុត ។

## ប្រការ ៤២

## អំពីការជូនដំណឹងពីករណីចាប់ខ្លួន ឃុំខ្លួន ឬ ចោទប្រកាន់

ក្នុងករណីមានការចាប់ខ្លួន ឬការឃុំខ្លួនបណ្តោះអាសន្នរង់ចាំការកាត់ទោសនៃសមាជិកបុគ្គលិកកុងស៊ុលណាម្នាក់ ឬមានការចោទប្រកាន់ពីបទព្រហ្មទ័ណ្ឌចំពោះជននោះ រដ្ឋម្ចាស់ផ្ទះត្រូវជូនដំណឹងយ៉ាងប្រញាប់ដល់ប្រធានស្ថានកុងស៊ុល ។ ប្រសិនបើប្រធានប៉ុស្តិ៍កុងស៊ុលខ្លួនឯងត្រូវពាក់ព័ន្ធនឹងវិធានការណាមួយក្នុងបណ្តាវិធានការទាំងនោះ រដ្ឋម្ចាស់ ផ្ទះត្រូវជូនដំណឹងពីបញ្ហានេះទៅរដ្ឋដាក់កុងស៊ុលតាមផ្លូវការទូត ។

## ប្រការ ៤៣

## អភ័យឯកសិទ្ធិនៃការជំនុំជំរះក្តី

១- មន្ត្រីកុងស៊ុល និងនិយោជិកកុងស៊ុលមិនអាចត្រូវអាជ្ញាធរខាងតុលាការ និងរដ្ឋបាលរបស់រដ្ឋម្ចាស់ផ្ទះជំនុំជំរះបានទេ ចំពោះសកម្មភាពទាំងឡាយដែលបានធ្វើក្នុងការបំពេញមុខងារកុងស៊ុល ។

២- កំប៉ុន្តែបណ្តាបទបញ្ញត្តិក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះ មិនអនុវត្តក្នុងករណីបណ្តឹងបទរដ្ឋប្បវេណី ដូចខាងក្រោមនេះ :

ក- បណ្តាលមកពីការចុះកិច្ចសន្យាធ្វើឡើងដោយមន្ត្រីកុងស៊ុលណាម្នាក់ ឬ និយោជិតកុងស៊ុលណាម្នាក់ដែលមិនបានចុះកិច្ចសន្យាដោយជាក់លាក់ក្នុងនាមជាភ្នាក់ងារ របស់រដ្ឋដាក់កុងស៊ុល ឬ

ខ- ប្តឹងចោទដោយជនដទៃម្នាក់ពីការខូចខាត បណ្តាលពីគ្រោះថ្នាក់កើតឡើងក្នុងរដ្ឋម្ចាស់ផ្ទះដោយរថយន្ត នាវា ឬ អាកាសយាន ។

## ប្រការ ៤៤

## ភាតព្វកិច្ចឆ្លើយជាសាក្សី

១- បណ្តាសមាជិកនៃប៉ុស្តិ៍កុងស៊ុល អាចត្រូវកោះហៅអោយចូលឆ្លើយជាសាក្សីនៅពេលមានបណ្តឹងតុលាការ និងរដ្ឋបាល ។ និយោជិតកុងស៊ុល ឬ សមាជិកនៃបុគ្គលិកបំរើការណាម្នាក់មិនត្រូវបដិសេធក្នុងការឆ្លើយជាសាក្សីទេ លើកលែងតែករណីទាំងឡាយដែលបានចែងក្នុងកថាខ័ណ្ឌ ៣ នៃប្រការនេះ។ ប្រសិនបើមន្ត្រីកុងស៊ុលម្នាក់បដិសេធមិនឆ្លើយជាសាក្សី គ្មានវិធានការបង្ខិតបង្ខំ ឬ ទណ្ឌកម្មណាមួយអាចត្រូវយកមកអនុវត្តលើមន្ត្រីនោះបានទេ។

២- អាជ្ញាធរដែលទាមទារចំលើយជាសាក្សីរបស់មន្ត្រីកុងស៊ុលណាម្នាក់ ត្រូវជៀសវាងកុំអោយរំខានដល់ការបំពេញមុខងាររបស់មន្ត្រីនោះ ។ អាជ្ញាធរអាចទទួលយកចំលើយជាសាក្សីនៅលំនៅស្ថាន ឬ នៅប៉ុស្តិ៍កុងស៊ុល ឬ ទទួលយកចំលើយជាលាយលក្ខណ៍អក្សររបស់មន្ត្រីនោះនៅគ្រប់ពេលវេលាដែលអាចធ្វើទៅបាន ។

៣- បណ្តាសមាជិកនៃប៉ុស្តិ៍កុងស៊ុលមិនមានការចាំបាច់ត្រូវផ្តល់ភស្តុតាងស្តីពីបញ្ហាទាំងឡាយដែលទាក់ទងដល់ការបំពេញមុខងាររបស់ខ្លួន និងមិនចាំបាច់បង្ហាញលិខិតឆ្លើយឆ្លង និងឯកសារជាផ្លូវការផ្សេងៗ ដែលទាក់ទងដល់បញ្ហានោះទេ ។ សមាជិកទាំងនោះក៏មានសិទ្ធិបដិសេធមិនផ្តល់ភស្តុតាងក្នុងនាមជាសាក្សីជំនាញខាងច្បាប់របស់រដ្ឋដាក់កុងស៊ុល ។

## ប្រការ ៤៥

## ការបដិសេធមិនទទួលយកនូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ

១- រដ្ឋដាក់កុងស៊ុលអាចបដិសេធមិនទទួលយកបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិទាក់ទងនឹងសមាជិកណាម្នាក់នៃប៉ុស្តិ៍កុងស៊ុលដែលបានចែងក្នុងប្រការ ៤១-៤៣ និង ៤៤ ។

២- វៀរលែងតែបណ្តាបទបញ្ញត្តិក្នុងកថាខ័ណ្ឌ ៣ នៃប្រការនេះចេញការបដិសេធត្រូវតែធ្វើដោយជាក់លាក់ជានិច្ច និង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅរដ្ឋម្ចាស់ផ្ទះ ។

៣- ប្រសិនបើមន្ត្រីកុងស៊ុលម្នាក់ ឬនិយោជិតកុងស៊ុលម្នាក់ដាក់ពាក្យបណ្តឹងក្នុងរឿងមួយដែលខ្លួនអាចទទួលអភ័យឯកសិទ្ធិនៃការជំនុំជំរះក្តីស្របតាមប្រការ ៤៣ មន្ត្រីឬនិយោជិតកុងស៊ុលនោះពុំអាចលើកសំអាងពីអភ័យឯកសិទ្ធិនៃការជំនុំជំរះក្តីចំពោះរាល់បណ្តឹងតបវិញដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបណ្តឹងដើម ។

៤- ការបដិសេធមិនទទួលយកនូវអភ័យឯកសិទ្ធិនៃការជំនុំជំរះក្តីសំរាប់បណ្តឹងរដ្ឋប្បវេណី ឬ រដ្ឋបាល មិនបានចាត់ទុកថាជាការបដិសេធមិនទទួលយកអភ័យឯកសិទ្ធិ នៃវិធានការអនុវត្តសាលក្រមទេ ។ ចំពោះវិធានការអនុវត្តសាលក្រមនេះចាំបាច់ត្រូវមានការបដិសេធមួយដោយឡែក ។

## ប្រការ ៤៦

## ការរួចផុតពីការចុះបញ្ជីជនបរទេស និង ការអនុញ្ញាតអោយស្នាក់នៅ

១- មន្ត្រីកុងស៊ុល និងនិយោជិតកុងស៊ុលក៏ដូចជាសមាជិកគ្រួសារទាំងឡាយរបស់គេដែលរស់នៅជាមួយ ត្រូវបានរួចផុតពីកាតព្វកិច្ចទាំងអស់ដែលមានចែងក្នុងច្បាប់ និងបទបញ្ញត្តិទាំងឡាយរបស់រដ្ឋម្ចាស់ផ្ទះ ស្តីអំពីការចុះបញ្ជីជនបរទេស និងការអនុញ្ញាតអោយស្នាក់នៅ។

២- ក៏ប៉ុន្តែ បណ្តាបទបញ្ញត្តិក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះមិនអនុវត្តចំពោះនិយោជិតកុងស៊ុលដែលមិនមែនជានិយោជិតអចិន្ត្រៃយ៍របស់រដ្ឋដាក់កុងស៊ុល ឬ ដែលធ្វើសកម្មភាពឯកជនមានលក្ខណៈរកកំរៃក្នុងរដ្ឋម្ចាស់ផ្ទះ និងមិនអាចអនុវត្តបានចំពោះ សមាជិកណាម្នាក់នៃគ្រួសាររបស់និយោជិតនោះ ។

## ប្រការ ៤៧

## ការរួចផុតពីការកាន់ប័ណ្ណការងារ

១- ចំពោះសេវាទាំងឡាយដែលបានធ្វើសំរាប់រដ្ឋដាក់កុងស៊ុល សមាជិកនៃប៉ុស្តិ៍កុងស៊ុលត្រូវបានរួចពីកាតព្វកិច្ចក្នុងការកាន់បណ្ណការងារដែលកំណត់ដោយច្បាប់ និងបទបញ្ញត្តិទាំងឡាយរបស់រដ្ឋម្ចាស់ផ្ទះ ស្តីពីការប្រើប្រាស់កំលាំងពលកម្មបរទេស ។

២- បណ្តាសមាជិកនៃបុគ្គលិកឯកជននៃមន្ត្រីកុងស៊ុល និងបណ្តានិយោជិតកុងស៊ុលត្រូវបានរួចពីកាតព្វកិច្ចដែលបានចែងក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះ ប្រសិនបើអ្នកទាំងនោះមិនមានធ្វើការងារឯកជនអ្វីផ្សេងទៀត មានលក្ខណៈរកកំរៃក្នុងរដ្ឋម្ចាស់ផ្ទះ ។

## ប្រការ ៤៨

## ការរួចផុតពីរបបសន្តិសុខសង្គម

១- ដោយស្ថិតក្រោម ខ ទាំងឡាយនៃកថាខ័ណ្ឌ ៣ នៃប្រការនេះ សមាជិកនៃប៉ុស្តិ៍កុងស៊ុលដែលបានបំពេញសេវាកម្មដើម្បីរដ្ឋដាក់កុងស៊ុល និងគ្រួសាររបស់គេដែលរស់នៅជាមួយត្រូវបានរួចផុតពីបណ្តាបញ្ញត្តិនៃសន្តិសុខសង្គមដែលអនុវត្តនៅក្នុងរដ្ឋម្ចាស់ផ្ទះ។

២- ការរួចផុតពីរបបសន្តិសុខសង្គមដែលបានចែងក្នុងកថាខ័ណ្ឌ១នៃប្រការនេះ ក៏ត្រូវបានអនុវត្តផងដែរចំពោះសមាជិកនៃបុគ្គលិកឯកជន ដែលបំរើការងារដាច់មុខអោយប៉ុស្តិ៍កុងស៊ុលក្នុងលក្ខណ: ដូចនេះ :

ក-ជននោះមិនមែនជាពលរដ្ឋនៃរដ្ឋម្ចាស់ផ្ទះ ឬ ក៏គ្មានទីលំនៅជាអចិន្ត្រៃយ៍ក្នុងរដ្ឋ។

ខ-ជននោះស្ថិតក្រោមបណ្តាបញ្ញត្តិនៃសន្តិសុខសង្គម ដែលចូលជាធរមានក្នុងរដ្ឋដាក់កុងស៊ុល ឬ ក្នុងរដ្ឋមួយផ្សេងទៀត ។

៣- សមាជិកនៃប៉ុស្តិ៍កុងស៊ុល ដែលជួលបុគ្គលទាំងឡាយដែលការរួចផុតពីរបបសន្តិសុខសង្គមដូចចែងក្នុងកថាខ័ណ្ឌ ២ នៃប្រកាសនេះមិនបានអនុវត្តចំពោះពួកគេទេនោះ ត្រូវគោរពកាតព្វកិច្ចដែលបណ្តាបញ្ញត្តិស្តីពីសន្តិសុខសង្គមរបស់រដ្ឋម្ចាស់ផ្ទះទំលាក់បន្ទុកទៅលើអ្នកជួល ។

៤- ការរួចផុតីរបបសន្តិសុខសង្គមដែលចែងក្នុងកថាខ័ណ្ឌ ១ និង ២ នៃប្រការនេះមិនបានបដិសេធការចូលរួមដោយស្ម័គ្រចិត្តក្នុងរបបសន្តិសុខសង្គមរបស់រដ្ឋម្ចាស់ផ្ទះ កាលណាការចូលរួមនេះត្រូវរដ្ឋនេះយល់ព្រម ។

## ប្រការ ៤៩

## ការរួចផុតពីសារពើពន្ធ

១- មន្ត្រីកុងស៊ុល និងនិយោជិតកុងស៊ុល ក៏ដូចជាគ្រួសាររបស់គេដែលរស់នៅជាមួយត្រូវបានរួចផុតពីពន្ធដារ និងអាករជាតិ តំបន់ និងឃុំ លើរូបកាយ ឬ លើទ្រព្យសម្បត្តិលើកលែងតែ :

ក- ពន្ធដារមិនចំពោះទាំងឡាយដែលតាមធម្មតាត្រូវបានបញ្ចូលទៅក្នុងតំលៃទំនិញ ឬ សេវា

ខ- ពន្ធ និងអាករលើអសង្ហារិមទ្រព្យឯកជនស្ថិតនៅលើទឹកដីនៃរដ្ឋម្ចាស់ផ្ទះ ដោយស្ថិតក្រោម ខ ទាំងឡាយនៃប្រការ ៣២

គ- ពន្ធលើអចលនទ្រព្យលើការស្នងមរតក និងលើការផ្ទេរដែលត្រូវបានដកហូតដោយរដ្ឋម្ចាស់ផ្ទះដោយស្ថិតក្រោម ខ ទាំងឡាយនៃកថាខ័ណ្ឌ ខ នៃប្រការ ៥១

ឃ- ពន្ធ និងអាករលើប្រាក់ចំណូលឯកជន រួមទាំងប្រាក់ចំណេញជាមូលនិធិដែលមានប្រភពក្នុងរដ្ឋម្ចាស់ផ្ទះ និងពន្ធលើមូលនិធិដែលដកហូតលើវិនិយោគ ដែលបានធ្វើនៅតាមសហគ្រាសពាណិជ្ជកម្ម ឬហិរញ្ញវត្ថុនៅក្នុងរដ្ឋម្ចាស់ផ្ទះ ។

ង- ពន្ធ និងអាករដែលដកហូតលើប្រាក់កំរៃ បានមកពីការងារឯកជនដែលបានធ្វើ

ច- ពន្ធចុះបញ្ជីការ ពន្ធក្រឡាបញ្ជី ពន្ធបញ្ចាំ និងតែមដែលស្ថិតក្រោម ខ ទាំងឡាយនៃប្រការ ៣២ ។

២- សមាជិកនៃបុគ្គលិកបំរើការងារ ត្រូវបានរួចផុតពីពន្ធ និងអាករលើប្រាក់បៀវត្សដែលខ្លួនបានទទួលពីការងាររបស់គេ ។

៣- សមាជិកនៃបុស្តិ៍កុងស៊ុលដែលជួលបុគ្គលផ្សេងៗ ដែលប្រាក់បៀវត្សមិនត្រូវរួចផុតពីពន្ធលើប្រាក់កំរៃក្នុងរដ្ឋម្ចាស់ផ្ទះនោះ ត្រូវគោរពកាតព្វកិច្ចដែលច្បាប់ និងបទបញ្ញត្តិទាំងឡាយរបស់រដ្ឋម្ចាស់ផ្ទះដែលបានទំលាក់បន្ទុកទៅលើនិយោជកក្នុងការហូតពន្ធលើប្រាក់កំរៃ ។

## ប្រការ ៥០

## ការរួចផុតពីពន្ធគយ និង ការត្រួតពិនិត្យរបស់គយ

១- យោងតាមច្បាប់ និងបទបញ្ញត្តិទាំងឡាយដែលខ្លួនអាចកំណត់យក រដ្ឋម្ចាស់ផ្ទះអនុញ្ញាត ការនាំចូល និងអោយរួចផុតពីរាល់ពន្ធគយ អាករ និងពន្ធរួមផ្សេងទៀត ក្រៅពីសោហ៊ុយនៃការតំកល់ទុកក្នុងឃ្លាំង ការដឹកជញ្ជូន និងសោហ៊ុយដែលត្រូវចាយវាយសំរាប់សេវាដូចគ្នាចំពោះ :

ក- វត្ថុសំរាប់ប្រើប្រាស់ជាផ្លូវការរបស់បុស្តិ៍កុងស៊ុល

ខ- វត្ថុសំរាប់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់មន្ត្រីកុងស៊ុល ឬ បណ្តាសមាជិកនៃគ្រួសាររបស់គេដែលរស់នៅជាមួយ រួមទាំងឥវ៉ាន់សំរាប់មកតាំងទីលំនៅរបស់គេ ។ ឥវ៉ាន់សំរាប់ប្រើប្រាស់មិនត្រូវអោយលើសពីចំនួនចាំបាច់សំរាប់ការប្រើប្រាស់ផ្ទាល់របស់សាម៉ីជនឡើយ ។

២- បណ្តានិយោជិតកុងស៊ុលទទួលបុព្វសិទ្ធិ និង ការរួចផុតដូចមានចែងក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះចំពោះវត្ថុដែលនាំចូលនៅពេលតាំងទីជាដំបូងរបស់ខ្លួន ។

៣- ឥវ៉ាន់ផ្ទាល់ខ្លួនដែលនាំមកជាមួយរបស់មន្ត្រីកុងស៊ុល និងបណ្តាសមាជិកនៃគ្រួសាររបស់មន្ត្រីទាំងនោះដែលរស់នៅជាមួយត្រូវបានរួចផុតពីការត្រួតពិនិត្យ ។ ឥវ៉ាន់ទាំងនោះនឹងត្រូវដាក់អោយត្រួតពិនិត្យលុះ

ត្រាតែមានមូលហេតុច្បាស់លាស់ថា ក្នុងឥវ៉ាន់នោះមានវត្ថុផ្សេងក្រៅពីវត្ថុដូចចែងក្នុងអនុកថាខ័ណ្ឌ ខ ក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះ ឬវត្ថុដែលការនាំចូល ឬនាំចេញត្រូវហាមឃាត់ដោយច្បាប់ និងបទបញ្ញត្តិទាំងឡាយរបស់រដ្ឋម្ចាស់ផ្ទះ ឬ ស្ថិតនៅក្រោមច្បាប់ និងបទបញ្ញត្តិទាំងឡាយនៃចត្តាឡីស័ករបស់រដ្ឋនេះ ។ ការត្រួតពិនិត្យនេះអាចធ្វើបានតែនៅចំពោះមុខនៃមន្ត្រីកុងស៊ុល ឬ សមាជិកនៃសាមីគ្រួសារ ។

## ប្រការ ៥១

## មរតករបស់សមាជិកប៉ុស្តិ៍កុងស៊ុលម្នាក់ ឬ សមាជិកម្នាក់នៃគ្រួសាររបស់ជននោះ

ក្នុងករណីមានសមាជិកម្នាក់នៃប៉ុស្តិ៍កុងស៊ុល ឬ សមាជិកម្នាក់នៃគ្រួសាររបស់គេដែលរស់នៅជាមួយទទួលមរណភាព រដ្ឋម្ចាស់ផ្ទះត្រូវ :

១- អនុញ្ញាតិអោយនាំចេញនូវសង្ហារឹមវត្ថុរបស់សព លើកលែងតែសង្ហារឹមវត្ថុដែលរកបានក្នុងរដ្ឋម្ចាស់ផ្ទះដែលការនាំចេញត្រូវហាមឃាត់នៅពេលមានមរណភាព

២- មិនត្រូវដកពន្ធជាតិ តំបន់ ឬ ឃុំលើមរតក ឬ លើការផ្ទេរចលនវត្ថុដែលមានវត្តមានក្នុងរដ្ឋម្ចាស់ផ្ទះ ដោយមានតែវត្តមាននៃសពនៅក្នុងរដ្ឋនេះតែប៉ុណ្ណោះ ក្នុងឋានៈជាសមាជិកនៃប៉ុស្តិ៍កុងស៊ុល ឬជាសមាជិកគ្រួសាររបស់សមាជិកម្នាក់នៃប៉ុស្តិ៍កុងស៊ុល ។

## ប្រការ ៥២

## ការរួចផុតពីការផ្តល់កំលាំងកាយ

រដ្ឋម្ចាស់ផ្ទះត្រូវអោយបណ្តាសមាជិកនៃប៉ុស្តិ៍កុងស៊ុល និងបណ្តាសមាជិកគ្រួសាររបស់គេដែលរស់នៅជាមួយបានរួចផុតពីរាល់ការផ្តល់កំលាំងកាយ និងរាល់សេវាកម្មជាផលប្រយោជន៍សាធារណៈ ទោះតាមរូបភាពណាផ្សេងទៀតក៏ដោយ និងពីបន្ទុកយោធា ដូចជាកំណែន វិភាគទាន និងលំនៅយោធា ។

## ប្រការ ៥៣

## ការចាប់ផ្តើម និង ការបញ្ចប់នូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិកុងស៊ុល

១- រាល់សមាជិកនៃស្ថានកុងស៊ុលទទួលនូវបុព្វសិទ្ធិ និង អភ័យឯកសិទ្ធិដែលកំណត់ដោយអនុសញ្ញានេះ គិតចាប់ពីថ្ងៃដែលគេចូលដល់ទឹកដីនៃរដ្ឋម្ចាស់ផ្ទះ ដើម្បីមកកាន់ការងាររបស់ខ្លួន ឬ គិតចាប់ពីថ្ងៃចូលបំពេញមុខងាររបស់ខ្លួននៅប៉ុស្តិ៍កុងស៊ុល ប្រសិនបើសមាជិកនោះបានស្នាក់នៅលើទឹកដីនោះរួចហើយ ។

២- បណ្តាសមាជិកគ្រួសារនៃមន្ត្រីប៉ុស្តិ៍កុងស៊ុលដែលរស់នៅជាមួយ រួមទាំងបណ្តាសមាជិកនៃបុគ្គលិកឯកជនរបស់គេទទួលនូវបុព្វសិទ្ធិ និង អភ័យឯកសិទ្ធិដែលចែងក្នុងអនុសញ្ញានេះ គិតចាប់ពីកាលបរិច្ឆេទដែលគេបានទទួលបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិស្របទៅតាមកថាខ័ណ្ឌ ១ នៃប្រការនេះ ឬគិតចាប់ពីកាលបរិច្ឆេទដែលពួកគេបានចូលក្នុងទឹកដីរដ្ឋម្ចាស់ផ្ទះ ឬគិតចាប់ពីកាលបរិច្ឆេទដែលពួកគេបានក្លាយជាសមាជិកគ្រួសារ ឬជាបុគ្គលិកឯកជន ។

៣- នៅពេលដែលមុខងាររបស់សមាជិកណាម្នាក់នៃប៉ុស្តិ៍កុងស៊ុលត្រូវបញ្ចប់បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់សមាជិកនោះ ព្រមទាំងបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់បណ្តាសមាជិកគ្រួសារដែលរស់នៅជាមួយ ឬ បណ្តាសមាជិកនៃបុគ្គលិកឯកជនរបស់គេ ត្រូវអស់ជាធម្មតានៅពេលដែលជននោះចាកចេញពីទឹកដីនៃរដ្ឋម្ចាស់ផ្ទះ ឬ ការផុតកំណត់នៃថេរវេលាសមស្របមួយដែលទុកអោយជននោះដើម្បីចាកចេញ ប៉ុន្តែបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ នោះនៅមានរហូតដល់ពេលនោះ ទោះបីមានវិវាទដោយអាវុធក៏ដោយ ។ ចំណែកឯជនទាំងឡាយដែលចែងក្នុងកថាខ័ណ្ឌ ២ នៃប្រការនេះ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់គេត្រូវអស់នៅពេលដែលជនទាំងនោះឈប់រស់នៅជាមួយ ឬ ឈប់បំរើការងារអោយសមាជិកម្នាក់នៃប៉ុស្តិ៍កុងស៊ុល ក៏ប៉ុន្តែក៏ត្រូវយល់ផងដែរថា ប្រសិនបើជនទាំងនោះមានបំណងចាកចេញពីទឹកដីនៃរដ្ឋម្ចាស់ផ្ទះនៅក្នុងថេរវេលាមួយដ៏សមស្រប បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់គេទាំងនោះ នៅមានរហូតដល់ពេលចេញដំណើររបស់គេ ។

៤- ក៏ប៉ុន្តែ ចំពោះការងារដែលមន្ត្រីកុងស៊ុល ឬ និយោជិតកុងស៊ុលបានធ្វើក្នុងការបំពេញមុខងាររបស់គេនោះ អភ័យឯកសិទ្ធិនៃការជំនុំជំរះនៅមានក្នុងរយៈពេលមួយគ្មានកំណត់ ។

៥- ក្នុងករណីមានសមាជិកម្នាក់នៃប៉ុស្តិ៍កុងស៊ុលទទួលមរណភាព បណ្តាសមាជិកនៃគ្រួសាររបស់គេដែលរស់នៅជាមួយបន្តប្រើប្រាស់នូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិដែលខ្លួនទទួលបានរហូតដល់កាលបរិច្ឆេទដែលជនទាំងនោះចាកចេញពីទឹកដីនៃរដ្ឋម្ចាស់ផ្ទះ ឬ រហូតដល់ពេលផុតកំណត់ថេរវេលាមួយដ៏សមស្របដែលទុកអោយជនទាំងនោះដើម្បីចាកចេញ ។

## ប្រការ ៥៤

## កាតព្វកិច្ចនៃបណ្តារដ្ឋដទៃ

១- ប្រសិនបើមន្ត្រីកុងស៊ុលឆ្លងកាត់ ឬ ស្ថិតនៅលើទឹកដីនៃរដ្ឋដទៃមួយទៀតដែលបានផ្តល់ទិដ្ឋាការអោយមន្ត្រីនេះ ក្នុងករណីដែលទិដ្ឋាការនេះត្រូវមានជាចាំបាច់ ដើម្បីទៅបំពេញមុខងារ ឬ ទៅកាន់តំណែង ឬដើម្បីវិលត្រឡប់ទៅរដ្ឋដាក់កុងស៊ុលវិញ រដ្ឋដទៃនោះត្រូវផ្តល់អោយមន្ត្រីនោះនូវអភ័យឯកសិទ្ធិដូចចែងក្នុងប្រការផ្សេងៗនៃអនុសញ្ញានេះដែលអាចមានប្រយោជន៍ដល់ការឆ្លងកាត់ ឬ ការវិលត្រឡប់របស់ជននោះ ។ រដ្ឋដទៃនោះត្រូវធ្វើដូចគ្នាដែរ ចំពោះបណ្តាសមាជិកគ្រួសារដែលរស់នៅជាមួយ និងដែលទទួលបាននូវបុព្វសិទ្ធិ

និងអភ័យឯកសិទ្ធិដែលរួមដំណើរជាមួយមន្ត្រីកុងស៊ុល ឬ ដែលធ្វើដំណើរដោយឡែកដើម្បីទៅរស់នៅជាមួយមន្ត្រីកុងស៊ុល ឬ វិលត្រឡប់ទៅកាន់រដ្ឋដាក់កុងស៊ុលវិញ ។

២- ក្នុងលក្ខណៈប្រហាក់ប្រហែលគ្នានឹងលក្ខណៈដែលបានចែងក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះ រដ្ឋដទៃមិនត្រូវធ្វើឧបសគ្គដល់ការឆ្លងកាត់នៅលើទឹកដីខ្លួនរបស់បណ្ដាសមាជិកដទៃទៀតនៃប៉ុស្តិ៍កុងស៊ុល និងបណ្ដាសមាជិកគ្រួសាររបស់គេដែលរស់ជាមួយ ។

៣- បណ្ដារដ្ឋដទៃត្រូវយល់ព្រមផ្ដល់អោយនូវសេរីភាព និងការគាំពារនូវលិខិតឆ្លើយឆ្លងជាផ្លូវការនឹងការទាក់ទងជាផ្លូវការដ៏ល្អទៀតនៅពេលកំពុងឆ្លងកាត់ រួមទាំងលិខិតជាសញ្ញានិងលេខសំងាត់ ។ សេរីភាព និង ការគាំពារនេះដូចគ្នានឹងសេរីភាពដែលរដ្ឋម្ចាស់ផ្ទះចាំបាច់ត្រូវផ្ដល់ យោងតាមអនុសញ្ញានេះ ។ បណ្ដារដ្ឋដទៃទាំងនោះត្រូវយល់ព្រមផ្ដល់អោយនូវសិទ្ធិមិនត្រូវបំពារបំពាន និងការគាំពារដូចគ្នានឹងសិទ្ធិមិនត្រូវបំពារបំពាន និងការគាំពារដែលរដ្ឋម្ចាស់ផ្ទះចាំបាច់ត្រូវផ្ដល់ យោងតាមអនុសញ្ញានេះដល់បណ្ដាហិបកុងស៊ុល ដែលបានទទួលទិដ្ឋាការ ប្រសិនបើចាំបាច់ត្រូវមានទិដ្ឋាការនេះ និងដល់បណ្ដាហិបកុងស៊ុលដែលឆ្លងកាត់ ។

៤- បណ្ដាកាតព្វកិច្ចនៃរដ្ឋដទៃទាំងឡាយក្នុងក្របខ័ណ្ឌនៃកថាខ័ណ្ឌ ១-២ និង ៣ នៃប្រការនេះ អនុវត្តផងដែរចំពោះជនទាំងឡាយដែលមានចែងក្នុងកថាខ័ណ្ឌទាំងនេះ ក៏ដូចជាបណ្ដាការទាក់ទងជាផ្លូវការ និងបណ្ដាហិបកុងស៊ុល កាលបើវត្តមាននៃជន និងវត្ថុទាំងនេះនៅលើទឹកដីនៃរដ្ឋដទៃកើតឡើងដោយករណីមានប្រធានសក្តិ ។

## ប្រការ ៥៥

## ការគោរពច្បាប់ និងបទបញ្ជានានារបស់រដ្ឋម្ចាស់ផ្ទះ

១- ដោយមិនបោះបង់នូវបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់ខ្លួន ជនទាំងអស់ណាដែលទទួលនូវ បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិនេះ មានករណីកិច្ចត្រូវគោរពច្បាប់ និង បទបញ្ជាទាំងឡាយ របស់រដ្ឋម្ចាស់ផ្ទះ ។ ជនទាំងនោះក៏មានករណីកិច្ចមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋ នេះផងដែរ ។

២- បណ្ដាទីស្ថានកុងស៊ុលនឹងមិនត្រូវបានប្រើប្រាស់តាមបែបបទណាមួយដែលមិនសមស្រប នឹងការបំពេញមុខងារកុងស៊ុលទេ ។

៣- បណ្ដាបញ្ញត្តិក្នុងកថាខ័ណ្ឌ ២ នៃប្រការនេះមិនបំបាត់ចោលនូវលទ្ធភាពតាំងបង្កើតការិយាល័យនៃអង្គការ ឬ ទីភ្នាក់ងារផ្សេងទៀតក្នុងចំណែកណាមួយនៃអាគារដែលប៉ុស្តិ៍កុងស៊ុលតាំងនៅទេ ល្គឹកណាអាគារដែលប្រើប្រាស់ជាការិយាល័យទាំងនោះ ត្រូវបានខ័ណ្ឌផ្ដាច់ពីអាគារដែលប្រើប្រាស់ដោយប៉ុស្តិ៍កុងស៊ុល ។ ក្នុងករណីនេះ ការិយាល័យចែងខាងលើក្នុងក្របខ័ណ្ឌនៃ អនុសញ្ញានេះមិនត្រូវចាត់ទុកថា ជាចំណែកនៃប៉ុស្តិ៍កុងស៊ុលទេ ។

## ប្រការ ៥៦
## ការធានារ៉ាប់រងចំពោះការខូចខាតដល់អ្នកដទៃ

បណ្ដាសមាជិកនៃប៉ុស្តិ៍កុងស៊ុល ត្រូវសំរបខ្លួនតាមបណ្ដាកាតព្វកិច្ចដែលច្បាប់ និងបទបញ្ជាទាំងឡាយនៃរដ្ឋម្ចាស់ផ្ទះ បានកំណត់ស្ដីពីការធានារ៉ាប់រងនូវការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ក្នុងការប្រើប្រាស់នូវរាល់រថយន្ត នាវា ឬ អាកាសយាន ។

## ប្រការ ៥៧
## បណ្ដាបទបញ្ញត្តិពិសេស ស្ដីពីការងារឯកជនដែលមានលក្ខណៈរកកំរៃ

១- បណ្ដាមន្ត្រីកុងស៊ុលអាជីពនឹងមិនត្រូវធ្វើសកម្មភាពវិជ្ជាជីវៈ ឬ ពាណិជ្ជកម្មណាមួយក្នុងរដ្ឋម្ចាស់ផ្ទះដើម្បីរកកំរៃផ្ទាល់ខ្លួនឡើយ ។

២- បណ្ដាបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិចែងក្នុងជំពូកនេះនឹងមិនត្រូវបានផ្ដល់ទៅ :

ក- បណ្ដានិយោជិតកុងស៊ុល និងបណ្ដាសមាជិកនៃបុគ្គលិកបំរើការងារដែលបំពេញការងារឯកជនមានលក្ខណៈរកកំរៃក្នុងរដ្ឋម្ចាស់ផ្ទះ

ខ- បណ្ដាសមាជិកនៃគ្រួសារនៃជនណាម្នាក់ដូចមានចែងក្នុងអនុកថាខ័ណ្ឌ "ក" នៃកថាខ័ណ្ឌនេះ និងបណ្ដាសមាជិកបុគ្គលិកឯកជនរបស់គេ

គ- បណ្ដាសមាជិកគ្រួសារនៃសមាជិកម្នាក់នៃប៉ុស្តិ៍កុងស៊ុលដែលបំពេញការងារឯកជនខ្លួនឯងមានលក្ខណៈរកកំរៃក្នុងរដ្ឋម្ចាស់ផ្ទះ ។

## ជំពូក III
## របបដែលអាចអនុវត្តចំពោះមន្ត្រីកុងស៊ុលកិត្តិយស
## និង បណ្ដាប៉ុស្តិ៍កុងស៊ុលដែលដឹកនាំដោយមន្ត្រីទាំងនោះ

## ប្រការ ៥៨
## បញ្ញត្តិទូទៅ ស្ដីពីភាពងាយស្រួលនៃបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ

១- បណ្ដាបញ្ញត្តិទូទៅស្ដីពីភាពងាយស្រួលនៃបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ

- បណ្ដាប្រការ ២៨-២៩-៣០-៣៤-៣៥-៣៦-៣៧-៣៨ និង ៣៩ ក្នុងកថាខ័ណ្ឌ ៣ នៃប្រការ ៥៤ និង បណ្ដាកថាខ័ណ្ឌ ២ និង ៣ នៃប្រការ ៥៥ អនុវត្តចំពោះបណ្ដាប៉ុស្តិ៍កុងស៊ុលដែលដឹកនាំដោយមន្ត្រីកុងស៊ុលកិត្តិយស ។ម្យ៉ាងទៀតភាពងាយស្រួលនៃបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនៃប៉ុស្តិ៍កុងស៊ុលនេះ ត្រូវបានកំណត់ដោយប្រការ ៥៩-៦០ និង ៦២ ។

២- បណ្តាប្រការ ៤២ និង ៤៣ កថាខ័ណ្ឌ ៣ នៃប្រការ ៤៤ បណ្តាប្រការ ៤៥ និង ៥៣ និង កថាខ័ណ្ឌ ១ នៃប្រការ ៥៥ អនុវត្តចំពោះមន្ត្រីកុងស៊ុលកិត្តិយស ។ ម្យ៉ាងទៀត ភាពងាយស្រួលនៃបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិនៃមន្ត្រីកុងស៊ុលទាំងនេះ ត្រូវបានកំណត់ដោយប្រការ ៦៣-៦៤-៦៥-៦៦ និង ៦៧ ។

៣- បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិទាំងឡាយដែលចែងក្នុងអនុសញ្ញានេះ មិនត្រូវបានផ្តល់អោយ ដល់បណ្តាសមាជិកគ្រួសារនៃមន្ត្រីកុងស៊ុលកិត្តិយសណាម្នាក់ ឬ និយោជិតកុងស៊ុលណាម្នាក់ដែលបំរើការងារក្នុងប៉ុស្តិ៍កុងស៊ុលមួយ ដែលដឹកនាំដោយមន្ត្រីកុងស៊ុលកិត្តិយសម្នាក់ ។

៤- ការប្តូរទៅមកនូវហិបកុងស៊ុលរវាងប៉ុស្តិ៍កុងស៊ុល ២ តាំងនៅក្នុងប្រទេស ២ ផ្សេងពីគ្នាហើយដែលដឹកនាំដោយមន្ត្រីកុងស៊ុលកិត្តិយសអាចធ្វើបានលុះត្រាតែមានការយល់ព្រមពីរដ្ឋម្ចាស់ផ្ទះទាំងពីរ ។

## ប្រការ ៥៩

## ការការពារទីស្ថានកុងស៊ុល

រដ្ឋម្ចាស់ផ្ទះចាត់វិធានការណ៍ចាំបាច់ទាំងឡាយ ដើម្បីការពារទីតាំងទាំងឡាយនៃប៉ុស្តិ៍កុងស៊ុលមួយដែលដឹកនាំដោយមន្ត្រីកុងស៊ុលកិត្តិយសម្នាក់ និងទប់ស្កាត់មិនអោយទីស្ថានទាំងនោះត្រូវគេបំពារបំពាន ឬ ធ្វើអោយខូចខាត និង មិនអោយមានកករល្អក់ដល់សន្តិសុខនៃស្ថានកុងស៊ុល ឬ កិត្តិយសរបស់ស្ថានកុងស៊ុលត្រូវអាប់អោន ។

## ប្រការ ៦០

## ការរួចផុតពីសារពើពន្ធនៃបណ្តាទីស្ថានកុងស៊ុល

១- បណ្តាទីស្ថាននៃប៉ុស្តិ៍កុងស៊ុលមួយដែលដឹកនាំដោយមន្ត្រីកុងស៊ុលកិត្តិយសម្នាក់ ហើយដែលរដ្ឋដាក់កុងស៊ុលជាម្ចាស់ ឬ ជាអ្នកជួលត្រូវបានរួចពន្ធ និងអាករជាតិ តំបន់ ឬ ឃុំ គ្រប់ប្រភេទ ដរាបណាពន្ធទាំងនោះមិនមែនជាពន្ធដែលដកហូតជាកំរៃនៃការងារឯកជនដែល គេបានធ្វើអោយកុងស៊ុល ។

២- ការរួចផុតពីសារពើពន្ធដែលបានចែងក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះ មិនអនុវត្តចំពោះពន្ធ និងអាករទាំងនោះទេ កាលណាពន្ធ និងអាករទាំងនោះយោងតាមច្បាប់ និងបទបញ្ញត្តិទាំងឡាយរបស់រដ្ឋម្ចាស់ផ្ទះត្រូវជាបន្ទុករបស់បណ្តាជនដែលបានធ្វើកិច្ចសន្យាជាមួយរដ្ឋដាក់កុងស៊ុល ។

## ប្រការ ៦១

## សិទ្ធិមិនត្រូវគេបំពារបំពានរបស់បណ្ណសារដ្ឋាន និងឯកសារកុងស៊ុល

បណ្ណសារដ្ឋាន និងឯកសារទាំងឡាយនៃប៉ុស្តិ៍កុងស៊ុលមួយដែលដឹកនាំដោយមន្ត្រីកុងស៊ុលកិត្តិយស មិនត្រូវបានគេបំពារបំពាននៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែងប្រសិនបើបណ្ណសារដ្ឋាន និងឯកសារទាំងនោះ ត្រូវបានរក្សាទុកដោយឡែកពីក្រដាសស្នាម និងឯកសារដទៃផ្សេងទៀត និងជាពិសេសពីលិខិតឆ្លើយឆ្លង ឯកជនរបស់ប្រធានប៉ុស្តិ៍កុងស៊ុល ឬ ពីរាល់ជនដែលធ្វើការជាមួយប្រធានប៉ុស្តិ៍កុងស៊ុល ព្រមទាំងទ្រព្យសម្បត្តិ សៀវភៅ ឬ ឯកសារទាំងឡាយពាក់ព័ន្ធដល់មុខរបរ ឬ ជំនួញរបស់ជនទាំងនោះ ។

## ប្រការ ៦២

## ការរួចផុតពីពន្ធគយ

អាស្រ័យដោយច្បាប់ និងបទបញ្ញត្តិទាំងឡាយដែលខ្លួនអាចអនុម័តយក រដ្ឋម្ចាស់ផ្ទះអនុញ្ញាតិការនាំ ចូលព្រមទាំងផ្តល់ការរួចផុតពីពន្ធគយ អាករ និងពន្ធបន្ទាប់បន្សំដទៃទៀតក្រៅពីសោហ៊ុយសំរាប់ការថែរក្សា ទុកការដឹកជញ្ជូន និងសោហ៊ុយសំរាប់សេវាប្រហាក់ប្រហែលគ្នាចំពោះសំភារៈដូចខាងក្រោម ប្រសិនបើ សំភារៈទាំងនោះសំរាប់ប្រើប្រាស់ជាផ្លូវការរបស់ប៉ុស្តិ៍កុងស៊ុលដែលដឹកនាំដោយមន្ត្រីកុងស៊ុលកិត្តិយស : សញ្ញា ជាតិ ទង់ជាតិ ផ្លាកសំគាល់ ត្រាធំ និង ត្រាតូច សៀវភៅអាន លិខិតស្នាម បោះពុម្ពជាផ្លូវការ សង្ហារិមវត្ថុសំរាប់ការិយាល័យ សំភារៈប្រើប្រាស់សំរាប់ការិយាល័យ និងសំភារៈប្រហាក់ប្រហែលគ្នាដែល ផ្តល់មកអោយស្ថានកុងស៊ុលដោយរដ្ឋដាក់កុងស៊ុល ឬ តាមសំណើរបស់ប៉ុស្តិ៍កុងស៊ុល ។

## ប្រការ ៦៣

## នីតិវិធីព្រហ្មទណ្ឌ

កាលណាមាននីតិវិធីព្រហ្មទណ្ឌមួយត្រូវបានដាក់ចោទលើមន្ត្រីកុងស៊ុលកិត្តិយសណាម្នាក់ មន្ត្រីនោះត្រូវ តែចូលខ្លួននៅចំពោះមុខអាជ្ញាធរសមត្ថកិច្ច ។ ក៏ប៉ុន្តែ នីតិវិធីត្រូវធ្វើប្រកបដោយការគោរពចំពោះមន្ត្រីនោះ ដោយគិតទៅដល់តួនាទីជាផ្លូវការរបស់មន្ត្រីនោះ និងក្នុងលក្ខណៈមួយដែលរំខានតិចតួចដល់ការបំពេញមុខងារ កុងស៊ុល លើកលែងតែមន្ត្រីនោះត្រូវចាប់ខ្លួន ឬឃុំខ្លួន ។ បើកាលណាមាន ការចាំបាច់ត្រូវឃុំខ្លួនមន្ត្រីកុងស៊ុល កិត្តិយសណាម្នាក់ នីតិវិធីចោទប្រកាន់លើមន្ត្រីនោះត្រូវផ្តើម ធ្វើក្នុងកាលដ៏ឆាប់បំផុត ។

## ប្រការ ៦៤

## ការការពារមន្ត្រីកុងស៊ុលកិត្តិយស

រដ្ឋម្ចាស់ផ្ទះត្រូវតែផ្តល់ដល់មន្ត្រីកុងស៊ុលកិត្តិយសនូវការការពារ ដែលជាការចាំបាច់ដល់តួនាទីជាផ្លូវការរបស់មន្ត្រីនោះ ។

## ប្រការ ៦៥

## ការរួចផុតពីការចុះបញ្ជីនៃជនបរទេស និងប័ណ្ណស្នាក់អាស្រ័យ

មន្ត្រីកុងស៊ុលកិត្តិយស លើកលែងតែជនទាំងឡាយណាដែលប្រកបរបរវិជ្ជាជីវៈ ឬ ជំនួញក្នុងរដ្ឋម្ចាស់ផ្ទះដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ត្រូវរួចផុតពីកាតព្វកិច្ច ទាំងអស់ដែលកំណត់ដោយច្បាប់ និងបទបញ្ញត្តិនៃរដ្ឋម្ចាស់ផ្ទះ ស្តីពីការចុះបញ្ជីជនបរទេស និងប័ណ្ណស្នាក់អាស្រ័យ ។

## ប្រការ ៦៦

## ការរួចផុតពីសារពើពន្ធ

មន្ត្រីកុងស៊ុលកិត្តិយសត្រូវបានរួចផុតពីពន្ធ អាករទាំងអស់លើប្រាក់កំរៃ និងប្រាក់បៀវត្សដែលខ្លួនបានទទួលពីរដ្ឋដាក់កុងស៊ុលដោយសារការបំពេញមុខងារកុងស៊ុល ។

## ប្រការ ៦៧

## ការរួចផុតពីសេវាកម្មផ្ទាល់ខ្លួន និងការរួមចំណែកធានា

រដ្ឋម្ចាស់ផ្ទះត្រូវអោយមន្ត្រីកុងស៊ុលកិត្តិយសទាំងឡាយរួចផុតពីសេវាកម្មផ្ទាល់ខ្លួន និងសេវាកម្មសាធារណៈ ទាំងអស់ទោះប្រភេទណាក៏ដោយ ព្រមទាំងរួចផុតពីកាតព្វកិច្ចយោធាផ្សេងៗ ដូចជាកាតព្វកិច្ចពាក់ព័ន្ធ នឹងកំណែនជាសំភារៈ វិភាគទាន និងលំនៅយោធា ។

## ប្រការ ៦៨

## លក្ខណៈតាមធាន មិនបង្ខំនៃការដាក់អោយមានមន្ត្រីកុងស៊ុលកិត្តិយស

រដ្ឋនីមួយៗ មានសេរីភាពក្នុងការសំរេចថា ខ្លួននឹងចាត់តាំង ឬ នឹងទទួលនូវបណ្តាមន្ត្រីកុងស៊ុលកិត្តិយស ។

## ជំពូក IV

## បណ្តាបញ្ញត្តិទូទៅ :

## ប្រការ ៦៩

## បណ្តាភ្នាក់ងារកុងស៊ុលដែលមិនមែនជាប្រធានប៉ុស្តិ៍កុងស៊ុល

១- រដ្ឋនិមួយៗមានសេរីភាពក្នុងការសំរេចថាខ្លួននឹងដាក់ ឬនឹងទទួលទីភ្នាក់ងារកុងស៊ុលដឹកនាំដោយភ្នាក់ងារកុងស៊ុលដែលមិនត្រូវបានចាត់តាំងជាប្រធានស្ថានកុងស៊ុលពីរដ្ឋដាក់កុងស៊ុល ។

២- បណ្តាលក្ខ័ណ្ឌដែលក្នុងនោះបណ្តាទីភ្នាក់ងារកុងស៊ុលដែលចែងក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះ អាចបំពេញសកម្មភាពរបស់ខ្លួនបាន ក៏ដូចជាបុព្វសិទ្ធិ និង អភ័យឯកសិទ្ធិដែលភ្នាក់ងារកុងស៊ុលជាអ្នកគ្រប់គ្រងទីភ្នាក់ងារកុងស៊ុលទាំងនោះអាចទទួលបាន ត្រូវបានកំណត់ដោយកិច្ចព្រមព្រៀងរវាងរដ្ឋដាក់កុងស៊ុល និងរដ្ឋម្ចាស់ផ្ទះ ។

## ប្រការ ៧០

## ការបំពេញមុខងារកុងស៊ុលដោយបេសកកម្មទូត

១- បើ ខ ទាំងឡាយនៃអនុសញ្ញានេះក៏ អនុវត្តផងដែរចំពោះការបំពេញមុខងារកុងស៊ុលដោយបេសកកម្មទូតបើសិនសភាពការអនុញ្ញាត ។

២- បណ្តាឈ្មោះនៃសមាជិកទាំងឡាយនៃបេសកកម្មទូត ដែលចាត់តាំងអោយទទួលបន្ទុកផ្នែកកុងស៊ុល ឬ ចាត់អោយបំពេញមុខងារកុងស៊ុល ត្រូវជូនជាដំណឹងទៅក្រសួងការបរទេសនៃរដ្ឋម្ចាស់ផ្ទះ ឬទៅអាជ្ញាធរដែលក្រសួងនេះចាត់តាំងឡើង ។

៣- ក្នុងការបំពេញមុខងារកុងស៊ុល បេសកកម្មទូតអាចពាក់ព័ន្ធជាមួយ :

ក- បណ្តាអាជ្ញាធរមូលដ្ឋាននៃមណ្ឌលកុងស៊ុល

ខ- បណ្តាអាជ្ញាធរថ្នាក់មជ្ឈឹមនៃរដ្ឋម្ចាស់ផ្ទះប្រសិនបើច្បាប់ បទបញ្ញត្តិ និងទំនៀមទំលាប់នៃរដ្ឋម្ចាស់ផ្ទះ ឬក៏កិច្ចព្រមព្រៀងអន្តរជាតិ ស្តីពីបញ្ហានេះ អនុញ្ញាតអោយធ្វើបែបនេះ ។

៤- បណ្ដាបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់បណ្ដាសមាជិកនៃបេសកកម្មទូតដូចចែងក្នុងកថាខ័ណ្ឌ ២ នៃប្រការនេះនៅតែត្រូវបានកំណត់ដោយក្បួនខ្នាតនៃច្បាប់អន្តរជាតិទាក់ទងនឹងទំនាក់ទំនងការទូត ។

## ប្រការ ៧១

## ពលរដ្ឋ ឬជនដែលស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងរដ្ឋម្ចាស់ផ្ទះ

១- លើកលែងតែរដ្ឋម្ចាស់ផ្ទះផ្ដល់អោយនូវភាពងាយស្រួល បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិបន្ថែមទៀត មន្ត្រីកុងស៊ុលដែលជាពលរដ្ឋ ឬ អ្នកស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងរដ្ឋម្ចាស់ផ្ទះ ត្រូវទទួលអភ័យឯកសិទ្ធិនៃការជំនុំជំរះក្ដី និងសិទ្ធិមិនត្រូវគេបំពារបំពានលើរូបកាយ តែចំពោះសកម្មភាពជាផ្លូវការដែលបានធ្វើក្នុងការបំពេញមុខងាររបស់ខ្លួន និង បុព្វសិទ្ធិដូចចែងក្នុងកថាខ័ណ្ឌ ៣ នៃប្រការ ៤៤ ប៉ុណ្ណោះ ។ ចំពោះមន្ត្រីកុងស៊ុលទាំងនោះ រដ្ឋម្ចាស់ផ្ទះក៏ត្រូវប្រកាន់យកដូចដែរ នូវកាតព្វកិច្ចដែលចែងក្នុងប្រការ ៤២ ។ ប្រសិនមានបណ្ដឹងព្រហ្មទ័ណ្ឌត្រូវចោទប្រកាន់លើមន្ត្រីកុងស៊ុលណាម្នាក់ នីតិវិធីនោះត្រូវតែធ្វើតាមរបៀបណាដែលរំខានយ៉ាងតិចបំផុតដល់ការបំពេញមុខងារកុងស៊ុល លើកលែងតែសាមីជនត្រូវគេចាប់ខ្លួន ឬ ឃុំខ្លួន ។

២- បណ្ដាសមាជិកនៃបុគ្គលិកកុងស៊ុលដទៃទៀតដែលជាពលរដ្ឋ ឬ អ្នកស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងរដ្ឋម្ចាស់ផ្ទះ និងបណ្ដាសមាជិកនៃគ្រួសាររបស់គេ ក៏ដូចជាបណ្ដាសមាជិកនៃគ្រួសារមន្ត្រីកុងស៊ុលដែលចែងក្នុងកថាខ័ណ្ឌ ១ នៃប្រការនេះ ទទួលបាននូវភាពងាយស្រួលនៃបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិតែក្នុងលក្ខណៈដែលរដ្ឋនេះផ្ដល់ឱ្យប៉ុណ្ណោះ ។ បណ្ដាសមាជិកនៃគ្រួសាររបស់សមាជិកណាម្នាក់នៃបុគ្គលិកកុងស៊ុល និងបណ្ដាសមាជិកបុគ្គលិកឯកជនដែលជាពលរដ្ឋ ឬ អ្នកស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងរដ្ឋម្ចាស់ផ្ទះ ត្រូវទទួលបាននូវភាពងាយស្រួលបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិតែក្នុងលក្ខណៈដែលរដ្ឋនេះផ្ដល់ឱ្យប៉ុណ្ណោះ ។ ក៏ប៉ុន្តែរដ្ឋម្ចាស់ផ្ទះត្រូវធ្វើការជំនុំជំរះរបស់ខ្លួនលើជនទាំងនោះ ដោយធ្វើយ៉ាងណាកុំអោយរំខានហួសប្រមាណដល់ការបំពេញមុខងាររបស់បុគ្គលិកកុងស៊ុល ។

## ប្រការ ៧២

## ការមិនរើសអើង

១- ក្នុងការអនុវត្តន៍នូវបណ្ដា ខ នៃអនុសញ្ញានេះ រដ្ឋម្ចាស់ផ្ទះមិនត្រូវធ្វើការរើសអើងរវាងរដ្ឋទាំងឡាយឡើយ ។

២- ទោះយ៉ាងណាក្ដីមិនត្រូវចាត់ទុកថាជាការរើសអើងឡើយក្នុងករណី :

ក- នៅពេលដែលរដ្ឋម្ចាស់ផ្ទះអនុវត្តដោយតឹងតែងនូវខណាមួយនៃអនុសញ្ញានេះ ដោយសារមានការអនុវត្តន៍ដ៏តឹងតែងនៃ ខ នោះចំពោះបុគ្គលិកកុងស៊ុលរបស់ខ្លួនក្នុងរដ្ឋដាក់កុងស៊ុល ។

ខ- នៅពេលដែលបណ្តារដ្ឋបានផ្តល់អោយគ្នាទៅវិញទៅមកតាមទំលាប់ ឬតាមរយៈកិច្ចព្រមព្រៀងនូវការរាប់រកមួយប្រសើរជាងតំរូវការបណ្តា ខ ទាំងឡាយនៃអនុសញ្ញានេះ ។

## មាត្រា ៧៣

## ទំនាក់ទំនងរវាងអនុសញ្ញានេះ និង កិច្ចព្រមព្រៀងអន្តរជាតិដទៃទៀត

១- បណ្តា ខ នៃអនុសញ្ញានេះមិនប៉ះពាល់ដល់កិច្ចព្រមព្រៀងអន្តរជាតិដទៃទៀតដែលចូលជាធរមានក្នុងការទំនាក់ទំនងរវាងបណ្តារដ្ឋជាភាគីនៃកិច្ចព្រមព្រៀងទាំងនោះទេ ។

២- គ្មាន ខ ណាមួយនៃអនុសញ្ញានេះហាមឃាត់ដល់រដ្ឋផ្សេងៗមិនអោយចុះហត្ថលេខាលើកិច្ចព្រមព្រៀងអន្តរជាតិនានា ដែលបញ្ជាក់បន្ថែម ឬពង្រីកនូវបណ្តា ខនៃអនុសញ្ញានេះ ។

## ជំពូក V

## អវសានបញ្ញត្តិ

## មាត្រា ៧៤

## ការចុះហត្ថលេខា

អនុសញ្ញានេះនឹងបើកចំហសំរាប់ការចុះហត្ថលេខា ដោយរដ្ឋជាសមាជិកទាំងឡាយរបស់អង្គការសហប្រជាជាតិ ឬ ស្ថាប័នជំនាញណាមួយ ឬរដ្ឋជាភាគីនៃលក្ខន្តិកៈរបស់តុលាការអន្តរជាតិ និង រាល់រដ្ឋដទៃទៀតដែលត្រូវបានមហាសន្និបាតអង្គការសហប្រជាជាតិអញ្ជើញឱ្យចូលជាភាគីនៃអនុសញ្ញានេះ តាមបែបបទដូចតទៅ គឺរហូតដល់ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៦៣ នៅក្រសួងការបរទេសនៃសាធារណរដ្ឋអូទ្រីស នឹងបន្តទៅទៀតរហូតដល់ថ្ងៃទី ៣១ ខែ មិនា ឆ្នាំ ១៩៦៤ នៅទីស្នាក់ការនៃអង្គការសហប្រជាជាតិនៅក្រុងញូវយ៉ក ។

## មាត្រា ៧៥

## ការផ្តល់សច្ចាប័ន

អនុសញ្ញានេះ នឹងត្រូវដាក់សុំសច្ចាប័ន ។ លិខិតុបករណ៍សច្ចាប័ននឹងត្រូវតំកល់ទុកនៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

## ប្រការ៖ ៧៦

## ការចូលជាសមាជិក

អនុសញ្ញានេះនឹងត្រូវបានដាក់អោយរាល់រដ្ឋណាដែលស្ថិតនៅក្នុងប្រភេទមួយនៃប្រភេទទាំង ៤ ដូចចែងក្នុងប្រការ ៧៤ ចូលរួមជាសមាជិក ។ បណ្ណលិខិតុបករណ៍នៃការចូលជាសមាជិក ត្រូវតំកល់ទុកនៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

## ប្រការ៖ ៧៧

## ការចូលជាធរមាន

១- អនុសញ្ញានេះនឹងចូលជាធរមាន ៣០ ថ្ងៃក្រោយពេលតំកល់ទុកនៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិនូវលិខិតុបករណ៍សច្ចាប័ន ឬ ការភ្ជាប់ខ្លួនចូលជាភាគីចំនួន ២២ ។

២- ចំពោះរដ្ឋនិមួយៗដែលអោយសច្ចាប័នលើអនុសញ្ញា ឬភ្ជាប់ខ្លួនចូលជាភាគីបន្ទាប់ពីការតំកល់ទុកនូវលិខិតុបករណ៍សច្ចាប័ន ឬ ការភ្ជាប់ខ្លួនចូលជាភាគីចំនួន ២២ អនុសញ្ញានឹងចូលជាធរមាន ៣០ថ្ងៃបន្ទាប់ពីការ តំកល់ទុកលិខិតុបករណ៍សច្ចាប័ននេះ ។

## ប្រការ៖ ៧៨

## ការជូនដំណឹងដោយអគ្គលេខាធិការ

អគ្គលេខាធិការនៃអង្គការសហប្រជាជាតិនឹងជូនដំណឹងទៅរដ្ឋទាំងអស់ដែលស្ថិតក្នុងប្រភេទមួយនៃបណ្តាប្រភេទទាំង ៤ ចែងក្នុងប្រការ ៧៤ :

១- បណ្តាហត្ថលេខាដែលបានចុះលើអនុសញ្ញានេះ និង ការតំកល់ទុកលិខិតុបករណ៍សច្ចាប័ន ឬ ការភ្ជាប់ខ្លួនចូលជាភាគី ស្របតាមប្រការ ៧៤- ៧៥ និង ៧៦ ។

២- កាលបរិច្ឆេទដែលអនុសញ្ញានេះ នឹងត្រូវចូលជាធរមានស្របតាមប្រការ ៧៧ ។

## ប្រការ ៧៩

### អត្ថបទដែលមានតំលៃយកជាការបាន

ច្បាប់ដើមនៃអនុសញ្ញានេះ ជាភាសាអង់គ្លេស ចិន អេស្ប៉ាញ៉ូល បារាំង និង រុស្ស៊ី មានតំលៃស្មើគ្នា នឹងត្រូវតំកល់ទុកនៅអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ដែលនឹងចំលងបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម បញ្ជូនទៅគ្រប់រដ្ឋទាំងអស់ដែល ស្ថិតក្នុងប្រភេទមួយនៃបណ្តាប្រភេទទាំង ៤ ដូចចែងក្នុងប្រការ ៧៤ ។

អាស្រ័យហេតុនេះ តំណាងពេញសិទ្ធិដែលបានការអនុញ្ញាតត្រឹមត្រូវតាមច្បាប់ពីរដ្ឋាភិបាលរៀង១ខ្លួន បានចុះហត្ថលេខាលើអនុសញ្ញានេះ ។

ធ្វើនៅទីក្រុងវីយែន ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៦៣

# VIENNA CONVENTION ON CONSULAR RELATIONS

DONE AT VIENNA, ON 24 APRIL 1963

The States Parties to the present Convention,

Recalling that consular relations have been established between peoples since ancient times,

Having in mind the Purposes and Principles of the Charter of the United Nation concerning the sovereign equality of States, the maintenance of international peace and security, and the promotion of friendly relations among nations,

Considering that the United Nations Conference on Diplomatic Intercourse and Immunities adopted the Vienna Convention on Diplomatic Relations which was opened for signature on 18 April 1961,

Believing that an international convention on consular relations, privileges and immunities would also contribute to the development of friendly relations among nations, irrespective of their differing constitutional and social systems,

Realizing that the purpose of such privileges and immunities is not to benefit individuals but to ensure the efficient performance of functions by consular posts on behalf of their respective States,

Affirming that the rules of customary international law continue to govern matters not expressly regulated by the provisions of the present Convention,

Have agreed as follows:

## Article 1 DEFINITIONS

1. For the purposes of the present Convention, the following expressions shall have the meanings hereunder assigned to them:

(a) "consular post" means any consulate-general, consulate, vice-consulate or consular agency;

(b) "consular district" means the area assigned to a consular post for the exercise of consular functions;

(c) "head of consular post" means the person charged with the duty of acting in that capacity;

(d) "consular officer" means any person, including the head of a consular post, entrusted in that capacity with the exercise of consular functions;

(e) "consular employee" means any person employed in the administrative or technical service of a consular post;

(f) "member of the service staff" means any person employed in the domestic service of a consular post;

(g) "members of the consular post" means consular officers,consular employees and members of the service staff;

(h) "members of the consular staff" means consular officers, other than the head of a consular post, consular employees and members of the service staff;

(i) "member of the private staff" means a person who is employed exclusively in the private service of a member of the consular post;

(j) "consular premises" means the buildings or parts of buildings and the land ancillary thereto, irrespective of ownership, used exclusively for the purposes of the consular post;

(k) "consular archives" includes all the papers, documents, correspondence, books, films, tapes and registers of the consular post, together with the ciphers and codes, the card-indexes and any article of furniture intended for their protection or safekeeping.

2. Consular officers are of two categories, namely career consular officers and honorary consular officers. The provisions of Chapter II of the present Convention apply to consular posts headed by career consular officers; the provisions of Chapter III govern consular posts headed by honorary consular officers.

3. The particular status of members of the consular posts who are nationals or permanent residents of the receiving State is governed by Article 71 of the present Convention.

## *CHAPTER I CONSULAR RELATIONS IN GENERAL*

### *Section I ESTABLISHMENT AND CONDUCT OF CONSULAR RELATIONS*

### Article 2 ESTABLISHMENT OF CONSULAR RELATIONS

1. The establishment of consular relations between States takes place by mutual consent.

2. The consent given to the establishment of diplomatic relations between two States implies, unless otherwise stated, consent to the establishment of consular relations.

3. The severance of diplomatic relations shall not ipso facto involve the severance of consular relations.

## Article 3 EXERCISE OF CONSULAR FUNCTIONS

Consular functions are exercised by consular posts. They are also exercised by diplomatic missions in accordance with the provisions of the present Convention.

## Article 4 ESTABLISHMENT OF A CONSULAR POST

1. A consular post may be established in the territory of the receiving State only with that State's consent.

2. The seat of the consular post, its classification and the consular district shall be established by the sending State and shall be subject to the approval of the receiving State.

3. Subsequent changes in the seat of the consular post, its classification or the consular district may be made by the sending State only with the consent of the receiving State.

4. The consent of the receiving State shall also be required if a consulate-general or a consulate desires to open a vice-consulate or a consular agency in a locality other than that in which it is itself established.

5. The prior express consent of the receiving State shall also be required for the opening of an office forming part of an existing consular post elsewhere than at the seat thereof.

## Article 5 CONSULAR FUNCTIONS

Consular functions consist in:

(a) protecting in the receiving State the interests of the sending State and of its nationals, both individuals and bodies corporate, within the limits permitted by international law;

(b) furthering the development of commercial, economic, cultural and scientific relations between the sending State and the receiving State and otherwise promoting friendly relations between them in accordance with the provisions of the present Convention;

(c) ascertaining by all lawful means conditions and developments in the commercial, economic, cultural and scientific life of the receiving State, reporting thereon to the Government of the sending State and giving information to persons interested;

(d) issuing passports and travel documents to nationals of the sending State, and visas or appropriate documents to persons wishing to travel to the sending State;

(e) helping and assisting nationals, both individuals and bodies corporate, of the sending State;

(f) acting as notary and civil registrar and in capacities of a similar kind, and performing certain functions of an administrative nature, provided that there is nothing contrary thereto in the laws and regulations of the receiving State;

(g) safeguarding the interests of nationals, both individuals and bodies corporate, of the sending State in cases of succession mortis causa in the territory of the receiving State, in accordance with the laws and regulations of the receiving State;

(h) safeguarding, within the limits imposed by the laws and regulations of the receiving State, the interests of minors and other persons lacking full capacity who are nationals of the sending State, particularly where any guardianship or trusteeship is required with respect to such persons;

(i) subject to the practices and procedures obtaining in the receiving State, representing or arranging appropriate representation for nationals of the sending State before the tribunals and other authorities of the receiving State, for the purpose of obtaining, in accordance with the laws and regulations of the receiving State, provisional measures for the preservation of the rights and interests of these nationals, where, because of absence or any other reason, such nationals are unable at the proper time to assume the defence of their rights and interests;

(j) transmitting judicial and extrajudicial documents or executing letters rogatory or commissions to take evidence for the courts of the sending State in accordance with international agreements in force or, in the absence of such international agreements, in any other manner compatible with the laws and regulations of the receiving State;

(k) exercising rights of supervision and inspection provided for in the laws and regulations of the sending State in respect of vessels having the nationality of the sending State, and of aircraft registered in that State, and in respect of their crews;

(l) extending assistance to vessels and aircraft mentioned in sub-paragraph (k) of this Article and to their crews, taking statements regarding the voyage of a vessel, examining and stamping the ship's papers, and,without prejudice to the powers of the authorities of the receiving State, conducting investigations into any incidents which occurred during the voyage, and settling disputes of any kind between the master, the officers and the seamen in so far as this may be authorized by the laws and regulations of the sending State;

(m) performing any other functions entrusted to a consular post by the sending State which are not prohibited by the laws and regulations of the receiving State or to which no objection is taken by the receiving State or which are referred to in the international agreements in force between the sending State and the receiving State.

## Article 6 EXERCISE OF CONSULAR FUNCTIONS OUTSIDE THE CONSULAR DISTRICT

A consular officer may, in special circumstances, with the consent of the receiving State, exercise his functions outside his consular district.

## Article 7 EXERCISE OF CONSULAR FUNCTIONS IN A THIRD STATE

The sending State may, after notifying the States concerned, entrust a consular post established in a particular State with the exercise of consular functions in another State, unless there is express objection by one of the States concerned.

## Article 8 EXERCISE OF CONSULAR FUNCTIONS ON BEHALF OF A THIRD STATE

Upon appropriate notification to the receiving State, a consular post of the sending State may, unless the receiving State objects, exercise consular functions in the receiving State on behalf of a third State.

## Article 9 CLASSES OF HEADS OF CONSULAR POSTS

1. Heads of consular posts are divided into four classes, namely: (a)consuls-general;
(b) consuls;
(c) vice-consuls;
(d) consular agents.

2. Paragraph 1 of this Article in no way restricts the right of any of the Contracting Parties to fix the designation of consular officers other than the heads of consular posts.

## Article 10 APPOINTMENT AND ADMISSION OF HEADS OF CONSULAR POSTS

1. Heads of consular posts are appointed by the sending State and are admitted to the exercise of their functions by the receiving State.

2. Subject to the provisions of the present Convention, the formalities for the appointment and for the admission of the head of a consular post are determined by the laws, regulations and usages of the sending State and of the receiving State respectively.

## Article 11 THE CONSULAR COMMISSION OR NOTIFICATION OF APPOINTMENT

1. The head of a consular post shall be provided by the sending State with a document, in the form of a commission or similar instrument, made out for each appointment, certifying his capacity and showing, as a general rule, his full name, his category and class, the consular district and the seat of the consular post.

2. The sending State shall transmit the commission or similar instrument through the diplomatic or other appropriate channel to the Government of the State in whose territory the head of a consular post is to exercise his functions.

3. If the receiving State agrees, the sending State may, instead of a commission or similar instrument, send to the receiving State a notification containing the particulars required by paragraph 1 of this Article.

## Article 12 THE EXEQUATUR

1. The head of a consular post is admitted to the exercise of his functions by an authorization from the receiving State termed an exequatur, whatever the form of this authorization.

2. A State which refuses to grant an exequatur is not obliged to give to the sending State reasons for such refusal.

3. Subject to the provisions of Articles 13 and 15, the head of a consular post shall not enter upon his duties until he has received an exequatur.

## Article 13 PROVISIONAL ADMISSION OF HEADS OF CONSULAR POSTS

Pending delivery of the exequatur, the head of a consular post may be admitted on a provisional basis to the exercise of his functions. In that case, the provisions of the present Convention shall apply.

## Article 14 NOTIFICATION TO THE AUTHORITIES OF THE CONSULAR DISTRICT

As soon as the head of a consular post is admitted even provisionally to the exercise of his functions, the receiving State shall immediately notify the competent authorities of the consular district. It shall also ensure that the necessary measures are taken to enable the head of a consular post to carry out the duties of his office and to have the benefit of the provisions of the present Convention.

## Article 15 TEMPORARY EXERCISE OF THE FUNCTIONS OF THE HEAD OF A CONSULAR POST

1. If the head of a consular post is unable to carry out his functions or the position of head of consular post is vacant, an acting head of post may act provisionally as head of the consular post.

2. The full name of the acting head of post shall be notified either by the diplomatic mission of the sending State or, if that State has no such mission in the receiving State, by the head of the consular post, or, if he is unable to do so, by any competent authority of the sending State, to the Ministry for Foreign Affairs of the receiving State or to the authority designated by that Ministry. As a general rule, this notification shall be given in advance. The receiving State may make the admission as acting head of post of a person who is neither a diplomatic agent nor a consular officer of the sending State in the receiving State conditional on its consent.

3. The competent authorities of the receiving State shall afford assistance and protection to the acting head of post. While he is in charge of the post, the provisions of the present Convention shall apply to him on the same basis as to the head of the consular post concerned. The receiving State shall not, however, be obliged to grant to an acting head of post any facility, privilege or immunity which the head of the consular post enjoys only subject to conditions not fulfilled by the acting head of post.

4. When, in the circumstances referred to in paragraph 1 of this Article, a member of the diplomatic staff of the diplomatic mission of the sending State in the receiving State is designated by the sending State as an acting head of post, he shall, if the receiving State does not object thereto, continue to enjoy diplomatic privileges and immunities.

## Article 16 PRECEDENCE AS BETWEEN HEADS OF CONSULAR POSTS

1. Heads of consular posts shall rank in each class according to the date of the grant of the exequatur.

2. If, however, the head of a consular post before obtaining the exequatur is admitted to the exercise of his functions provisionally, his precedence shall be determined according to the date of the provisional admission; this precedence shall be maintained after the granting of the exequatur.

3. The order of precedence as between two or more heads of consular posts who obtained the exequatur or provisional admission on the same date shall be determined according to the dates on which their commissions or similar instruments or the notifications referred to in paragraph 3 of Article 11 were presented to the receiving State.

4. Acting heads of posts shall rank after all heads of consular posts and, as between themselves, they shall rank according to the dates on which they assumed their functions as acting heads of posts as indicated in the notifications given under paragraph 2 of Article 15.

5. Honorary consular officers who are heads of consular posts shall rank in each class after career heads of consular posts, in the order and according to the rules laid down in the foregoing paragraphs.

6. Heads of consular posts shall have precedence over consular officers not having that status.

## Article 17 PERFORMANCE OF DIPLOMATIC ACTS BY CONSULAR OFFICERS

1. In a State where the sending State has no diplomatic mission and is not represented by a diplomatic mission of a third State, a consular officer may, with the consent of the receiving State, and without affecting his consular status, be authorized to perform diplomatic acts. The performance of such acts by a consular officer shall not confer upon him any right to claim diplomatic privileges and immunities.

2. A consular officer may, after notification addressed to the receiving State, act as representative of the sending State to any inter-governmental organization. When so acting, he shall be entitled to enjoy any privileges and immunities accorded to such a representative by customary international law or by international agreements; however, in respect of the performance by him of any consular function, he shall not be entitled to any greater immunity from jurisdiction than that to which a consular officer is entitled under the present Convention.

## Article 18 APPOINTMENT OF THE SAME PERSON BY TWO OR MORE STATES AS A CONSULAR OFFICER

Two or more States may, with the consent of the receiving State, appoint the same person as a consular officer in that State.

## Article 19 APPOINTMENT OF MEMBERS OF CONSULAR STAFF

1. Subject to the provisions of Articles 20, 22 and 23, the sending State may freely appoint the members of the consular staff.

2. The full name, category and class of all consular officers, other than the head of a consular post, shall be notified by the sending State to the receiving State in sufficient time for the receiving State, if it so wishes, to exercise its rights under paragraph 3 of Article 23.

3. The sending State may, if required by its laws and regulations, request the receiving State to grant an exequatur to a consular officer other than the head of a consular post.
4. The receiving State may, if required by its laws and regulations, grant an exequatur to a consular officer other than the head of a consular post.

## Article 20 SIZE OF THE CONSULAR STAFF

In the absence of an express agreement as to the size of the consular staff, the receiving State may require that the size of the staff be kept within limits considered by it to be reasonable and normal, having regard to circumstances and conditions in the consular district and to the needs of the particular post.

## Article 21 PRECEDENCE AS BETWEEN CONSULAR OFFICERS OF A CONSULAR POST

The order of precedence as between the consular officers of a consular post and any change thereof shall be notified by the diplomatic mission of the sending State or, if that State has no such mission in the receiving State, by the head of the consular post, to the Ministry for Foreign Affairs of the receiving State or to the authority designated by that Ministry.

## Article 22 NATIONALITY OF CONSULAR OFFICERS

1. Consular officers should, in principle, have the nationality of the sending State.

2. Consular officers may not be appointed from among persons having the nationality of the receiving State except with the express consent of that State which may be withdrawn at any time.
3. The receiving State may reserve the same right with regard to nationals of a third State who are not also nationals of the sending State.

## Article 23 PERSONS DECLARED "NON GRATA"

1. The receiving State may at any time notify the sending State that a consular officer is persona non grata or that any other member of the consular staff is not acceptable. In that event, the sending State shall, as the case may be, either recall the person concerned or

terminate his functions with the consular post.

2. If the sending State refuses or fails within a reasonable time to carry out its obligations under paragraph 1 of this Article, the receiving State may, as the case may be, either withdraw the exequatur from the person concerned or cease to consider him as a member of the consular staff.

3. A person appointed as a member of a consular post may be declared unacceptable before arriving in the territory of the receiving State or, if already in the receiving State, before entering on his duties with the consular post. In any such case, the sending State shall withdraw his appointment.

4. In the cases mentioned in paragraphs 1 and 3 of this Article, the receiving State is not obliged to give to the sending State reasons for its decision.

## Article 24 NOTIFICATION TO THE RECEIVING STATE OF APPOINTMENTS, ARRIVALS AND DEPARTURES

1. The Ministry for Foreign Affairs of the receiving State or the authority designated by that Ministry shall be notified of:

(a) the appointment of members of a consular post, their arrival after appointment to the consular post, their final departure or the termination of their functions and any other changes affecting their status that may occur in the course of their service with the consular post;

(b) the arrival and final departure of a person belonging to the family of a member of a consular post forming part of his household and, where appropriate, the fact that a person becomes or ceases to be such a member of the family;

(c) the arrival and final departure of members of the private staff and, where appropriate, the termination of their service as such;

(d) the engagement and discharge of persons resident in the receiving State as members of a consular post or as members of the private staff entitled to privileges and immunities.

2. When possible, prior notification of arrival and final departure shall also be given.

## *Section II END OF CONSULAR FUNCTIONS*

## Article 25 TERMINATION OF THE FUNCTIONS OF A MEMBER OF A CONSULAR POST

The functions of a member of a consular post shall come to an end inter alia:

(a) on notification by the sending State to the receiving State that his functions have come to an end;

(b) on withdrawal of the exequatur;

(c) on notification by the receiving State to the sending State that the receiving State has ceased to consider him as a member of the consular staff.

## Article 26 DEPARTURE FROM THE TERRITORY OF THE RECEIVING STATE

The receiving State shall, even in case of armed conflict, grant to members of the consular post and members of the private staff, other than nationals of the receiving State, and to members of their families forming part of their households irrespective of nationality, the necessary time and facilities to enable them to prepare their departure and to leave at the earliest possible moment after the termination of the functions of the members concerned. In particular, it shall, in case of need, place at their disposal the necessary means of transport for themselves and their property other than property acquired in the receiving State the export of which is prohibited at the time of departure.

## Article 27 PROTECTION OF CONSULAR PREMISES AND ARCHIVES AND OF THE INTERESTS OF THE SENDING STATE IN EXCEPTIONAL CIRCUMSTANCES

1. In the event of the severance of consular relations between two States:

(a) the receiving State shall, even in case of armed conflict, respect and protect the consular premises, together with the property of the consular post and the consular archives;

(b) the sending State may entrust the custody of the consular premises, together with the property contained therein and the consular archives, to a third State acceptable to the receiving State;

